សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **សោម លីថូ**

**ហុង លីមផ័ង**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្រ្ត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

## សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ សោម លីថូ និង ហាង លីមផង ជានិស្សិតបរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី១៦ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាចាប់ ពីឆ្នាំ ២០១២ ដល់ ២០១៦។

សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **សោម ផល្លី** និង អ្នកម្ដាយ **គា ម៉ាន់លី** និង លោកឪពុក **ឡាង ស៊ាងហុង** និងអ្នកម្ដាយ **ខួន ស៊ីវខេង** ដែលលោកពិជាមានគុណដ៏ធំធេង ដែលលោកមិនត្រឹមតែផ្ដល់កំណើត ដល់រូបយើងខ្ញុំតែប៉ុណ្ណោះទេ លោកបានខិតខំថែរក្សា ចិញ្ចឹមបីបាច់ ផ្ដល់ដំបូន្មានល្អៗ ព្រមទាំង ខំប្រឹង ប្រែងអស់ពីកំលាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងដើម្បីឲ្យកូនក្លាយជាអ្នកមានចំណេះដឹងមួយរូបនៅ ក្នុងសង្គម។ លោកពិតជាបានជួននូវឧបសគ្គការលំបាកជាច្រើនប៉ុន្តែលោកមិនដែលត្អូញត្អែរ និងរុញរាទ្បើយ។ ដោយសារតែទទួលបានការលើកទឹកចិត្ត និងភាពកក់ក្ដៅរបសលោកទាំងពីរ ដែលជាកំលាំងចលករមួយដ៏មហិមាទើបយើងខ្ញុំក្លាយជានិស្សិតមួយរូប ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ព្រមទាំងមានលទ្ធភាពក្នុងការសរសេរសារណាមួយនេះបាន។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ** ដែលបានខិតខំអស់ពីកំលាំងកាយចិត្តពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង និងបង្ហាត់បង្រៀនរូបយើងខ្ញុំឲ្យទទួលបានចំណេះដឹងដើម្បីសរសេរបាននូវសារណានេះឡើង។

លោកសាស្ត្រាចារ្យ **គង់ សុភ័ក្ត្រ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងដឹកនាំ ណែនាំ បង្ហាត់បង្ហាញ ពន្យល់ កែតម្រូវ និងបានបង្កលក្ខណៈងាយស្រួលដល់ការសរសេរសារណានេះឡើង។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងពួងលើលោកនេះឲ្យជួយតាមថែរក្សាអស់លោកអ្នកមានគុណទាំងឡាយឲ្យជួបតែសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់វេលាកុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តអស់រយៈពេល បួនឆ្នាំ នៅ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** រួចមក យើងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនដោយរួមផ្សំពីការស្រាវជ្រាវពីស្ថានភាពជាក់ស្តែងនៃសង្គមផងដែរ។ សាកលវិទ្យាល័យនេះពិតជាគ្រឹះស្ថានកម្រិតឧត្តមសិក្សាមួយដែលប្រកបដោយគុណភាព និងប្រសិទ្ធិភាពតាមរយៈការផ្ទេរចំណេះដឹងពីសាស្រ្តាចារ្យទាំងឡាយ។ មិនត្រឹមតែចំណេះដឹងផ្នែកច្បាប់ដែលមានក្នុងសៀវភៅប៉ុណ្ណោះទេ តែសាលាក៏បានផ្តល់ឱកាសដល់និស្សិតទាំងអស់ឲ្យស្គាល់ពីការអនុវត្តផ្នែកច្បាប់នៃព្រះរាជាណាចក្រកម្ពុជាផងដែរ តាមរយៈកម្មវិធីពិសេសនានាដូចជា ថ្នាក់គ្លីនិកច្បាប់ ថ្នាក់ប្រឹក្សាក្ដីនិងថ្នាក់តស៊ូមតិជាដើម។

ស្នាដៃដ៏តូចមួយនេះជាការចងក្រងឡើង ដើម្បីជាសក្ខីភាពក្នុងការបញ្ជាក់នូវចំណេះដឹងដែលយើងខ្ញុំបានទទួលតាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេលបួនឆ្នាំកន្លងមក។ ខណៈនេះយើងខ្ញុំបានសម្រេចជ្រើសរើសនូវប្រធានបទមួយក្នុងចំណោមនីតិវិធីរដ្ឋប្បវេណីគឺ "**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**" មកធ្វើជាប្រធានបទសារណាក្នុងការបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

ការជ្រើសយកប្រធានបទនេះ ពីព្រោះយើងខ្ញុំយល់ឃើញថា តថភាពនៅក្នុង សង្គមខ្មែរនាពេលបច្ចុប្បន្ននេះ មានការកើតឡើងនូវវិវាទជាច្រើនតាមរយៈជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ជាគោល-ការណ៍ នៅក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី មាននីតិវិធីជាច្រើនទៀត ដូចជា ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ការចេញសាលក្រម។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ជួយសម្រួលដល់នីតិវិធីទាញហេតុដោយផ្ទាល់មាត់យ៉ាងច្រើន ដែលវាបានចម្រាញ់នូវអង្គហេតុចាំបាច់ក្នុងការទាមទាររបស់គូភាគីមុនបើកសវនាការ ដើម្បីទាញហេតុផល។

យើងខ្ញុំសង្ឃឹមថាឯកសារមួយនេះពិតជាអាចផ្តល់អត្ថប្រយោជន៍ដល់អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវពីនីតិវិធីបណ្តឹងរដ្ឋប្បវេណីឲ្យបានលម្អិត។ ឯកសារនេះអាចមានកំហុសខុសឆ្គង ដែលអាចកើតឡើងក្នុងប្រការណាមួយ ដូច្នេះហើយយើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងអចេតនា និងរីករាយក្នុងការទទួលយកការរិះគន់ដើម្បីស្ថាបនា ដើម្បីកែប្រែឯកសារនេះឲ្យប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១៖ ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**១.១. សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ............................................................ ៤

១.១.១. និយមន័យ ............................................................ ៥

១.១.២. គោលបំណង ............................................................ ៥

១.១.៣. គោលការណ៍ជាមូលដ្ឋាន ............................................................ ៥

១.១.៤. សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................................ ១១

**១.២. អំឡុងពេលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ............................................................ ១២

១.២.១. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................................ ១២

១.២.២. ការធ្វើកំណត់ហេតុ ............................................................ ១៤

១.២.២.១. អ្នកធ្វើកំណត់ហេតុ ............................................................ ១៤

១.២.២.២. ទម្រង់កំណត់ហេតុ ............................................................ ១៤

១.២.៣. សមត្ថកិច្ចដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................................ ១៥

១.២.៤. ទីតាំងសម្រាប់ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................................ ១៦

**ជំពូកទី២៖ សកម្មភាពនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**២.១. សកម្មភាពរបស់តុលាការ** ............................................................ ១៧

២.១.១. ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................................ ១៧

២.១.២. ការត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការ ........................ ១៨

២.១.២.១. ការស្នើសុំលើអង្គសេចក្តីនៃរឿងក្តី ........................................................... ១៨

២.១.២.២. ការបញ្ជាក់ចំណុចវិវាទ ........................................................................... ១៨

២.១.២.៣. ការរៀបចំភស្តុតាង .............................................................................. ២០

២.១.២.៤. ការបំបែក ឬការបញ្ចូលរឿងក្តី ................................................................ ២៦

២.១.៣. ដីកាសម្រេចដែលមិនមែនជាសាលក្រម ............................................................ ២៦

២.១.៣.១. របៀបចេញដីកាសម្រេច ........................................................................ ២៦

២.១.៣.២. អានុភាពនៃដីកាសម្រេច ....................................................................... ២៩

២.១.៣.៣. ការប្តឹងជំទាស់ពីដីកាសម្រេច ................................................................ ៣០

២.១.៣.៤. ករណីចេញដីកាសម្រេច ........................................................................ ៣១

២.១.៤. ការស្នើសុំផ្ទេរសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់តុលាការ ........................................... ៣៣

២.១.៤.១. ការផ្ទេរសមត្ថកិច្ចតុលាការ .................................................................... ៣៣

២.១.៤.២. ការដកហូតសមត្ថកិច្ចជំនុំជម្រះ ............................................................... ៣៤

**២.២. សកម្មភាពរបស់ភាគី** ............................................................................................ ៣៥

២.២.១. ការត្រៀមសម្រាប់ការទាញហេតុផលរបស់ភាគី ...................................................... ៣៥

២.២.១.១. ការដាក់សំណូមពរ ឬការឆ្លើយតប ............................................................ ៣៥

២.២.១.២. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន .................................................... ៣៧

២.២.១.៣. ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួន............................. ៣៨

២.២.១.៤. ការស្នើសុំឲ្យពិនិត្យភស្តុតាង ................................................................... ៣៩

២.២.១.៥. ការស្នើសុំឲ្យផ្លាស់ប្តូរសមត្ថកិច្ចតុលាការ បណ្តឹងជិតជិត និងការដកហូតសមត្ថកិច្ចតុលាការ.......................................................................... ៤០

២.២.១.៦. ការដកពាក្យបណ្តឹងរបស់ភាគី.......................................................................... ៤១

**២.៣. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលក្រោយៗទៀត**.......................................................... ៤៤

២.៣.១. សេចក្តីថ្លែងការណ៍.......................................................................... ៤៤

២.៣.១.១. សេចក្តីថ្លែងការណ៍អំពីឯកសារត្រៀមលើកទី១.......................................................... ៤៤

២.៣.១.២. សេចក្តីថ្លែងការណ៍ពីភស្តុតាង.......................................................................... ៤៤

**ជំពូកទី៣៖ ការបញ្ចប់ និងអានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**៣.១៖ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.......................................................... ៤៧

៣.១.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់.......................................................... ៤៧

៣.១.២. ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់.......................................................... ៤៧

**៣.២៖ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.......................................................... ៤៨

៣.២.១. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន.......................................................................... ៤៨

៣.២.២. ករណីលើកលែង.......................................................................... ៤៨

**សេចក្តីសន្និដ្ឋាន**.......................................................................... ៥០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ពីសម័យបុព្វកាល មនុស្សរស់នៅដោយត្រូវបានកម្រិតអំពីសិទ្ធិ និងកំណត់ព្រំដែននៃការប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួនឡើយ។ ដូច្នេះ មានទស្សនៈវិទូជនជាតិបារាំងម្នាក់ឈ្មោះ ហ្សង់ហ្សាក់ រូសូ (១៧១២- ១៧៧៨) បានបង្កើតនូវទ្រឹស្តីសង្គមមួយ សម្រាប់ជាទស្សនៈក្នុងការគ្រប់គ្រងសង្គម តាមរយៈកិច្ចសន្យាសង្គម។ យោងតាមទស្សនៈរបស់លោកយល់ឃើញថា មនុស្សរស់នៅតាមបែបធម្មជាតិរៀងៗខ្លួន គឺជាមូលហេតុនៃការបង្កជាទំនាស់ឡើង ដូច្នេះមនុស្សត្រូវលះបង់សិទ្ធិទាំងឡាយរបស់ខ្លួនទៅឲ្យសង្គម ហើយទទួលយកការបញ្ជាស៊ីវិលមកវិញ ពោលគឺគោរពច្បាប់ដែលបង្កើតចេញពីឆន្ទៈទូទៅរបស់សង្គម ដើម្បីបញ្ចប់រាល់វិវាទ ឬទំនាស់ ដែលចាំបាច់ត្រូវបង្កើតកិច្ចសន្យាស៊ីវិលមួយ។ ដូចប្រទេសកម្ពុជាផងដែរ ដែលពីអតីតកាលធ្លាប់ជាអរិយប្រទេសមួយដែលប្រកាន់យករបបរាជានិយម។ ចំពោះការដោះស្រាយទៅលើវិវាទនាសម័យនោះ គឺព្រះមហាក្សត្រជាអ្នកមានសមត្ថកិច្ចលើនីតិវិធីដោះស្រាយទាំងអស់ដោយគ្មានផ្អែកលើបទដ្ឋានគតិយុត្តណាមួយឡើយ។ លុះដល់សម័យអាណានិគមនិយមបារាំង កម្ពុជាបានចងក្រងនូវក្រមមួយចំនួនដែលទទួលឥទ្ធិពលពីបារាំង ដូចជា ក្រមទោសភរិយា ក្រមពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ក្រមព្រហ្មទណ្ឌ ជាដើម។ ប៉ុន្តែនីតិវិធីក្នុងការប្រព្រឹត្តទៅនៃបណ្តឹងផ្អែកលើប្បវេណី និងឆន្ទានុសិទ្ធិរបស់ចៅក្រម។ ជាអកុសល ប្រទេសមួយនេះបានធ្លាក់ចូលសម័យកាលដ៏ខ្មៅងងឹត គឺសម័យកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែលគ្រប់វិស័យ និងធនធានមនុស្សត្រូវបំផ្លាញ។ ក្រោមការរំដោះក្នុងឆ្នាំ១៩៧៩ កម្ពុជាចាប់ផ្តើមពីចំណុចសូន្យដោយធ្វើការវិវឌ្ឍន៍ខ្លួនពីបាតដៃទទេ។ ចំពោះប្រព័ន្ធយុត្តាធិការក៏បានពង្រឹងឡើងផងដែរ ក្រោមជំនួយរបស់បណ្តាប្រទេសនានា ដូចជា ប្រទេសជប៉ុន អាល្លឺម៉ង់ បារាំង ។ល។ ក្នុងឆ្នាំ២០០៦ អង្គការ JICA ប្រទេសជប៉ុន បានជួយក្នុងការចងក្រងក្រមនីតិវិធីរដ្ឋប្បវេណី។ នៅក្នុងនោះបានបែងចែកជា៩គន្លី និង ៥៨៨មាត្រា។

ជាការពិត ចំណងគតិយុត្តរវាងបុគ្គល និងបុគ្គលត្រូវបានបង្កើតឡើងដោយសកម្មភាពជាច្រើន ឬប្រតិបត្តិការពាណិជ្ជកម្ម ឬតាមរយៈការប្រាស្រ័យទាក់ទងគ្នា ដូចជា ការធ្វើកិច្ចសន្យា ការខ្ចី ការទិញដូរ ជាអាទិ៍។ ក្រោមក្របខណ្ឌនៃសកម្មភាពរបស់បុគ្គលទាំងនោះ ជម្លោះទាំងឡាយតែងតែកើតឡើងដោយមានការបំពាន ឬការមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា ដែលចាំបាច់ត្រូវស្វែងដំណោះស្រាយមួយដ៏ច្បាស់លាស់។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ មានវិធីសាស្ត្រជាច្រើន ដូចជា

នីតិវិធីដាស់តឿន ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បណ្តឹងរដ្ឋប្បវេណីដែលមានចំនួនទឹកប្រាក់តិចជាដើម។ យ៉ាងណាមិញ ដំណោះស្រាយទាំងនោះសុទ្ធតែស្ថិតក្រោមនីតិវិធីរដ្ឋប្បវេណី។

ក្នុងចង្កោមសាធារណជនទូទៅ ពួកគាត់តែងមានទស្សនៈថា នៅក្នុងដំណោះស្រាយនៃបណ្តឹង គឺតែងតែចាប់ផ្តើមពីការដាក់ពាក្យបណ្តឹងទៅតុលាការ ហើយរងចាំការដំណើរការនៃនីតិវិធីបណ្តឹងតាមរយៈការកោះហៅរបស់តុលាការ។ ប៉ុន្តែ ពួកគាត់ពុំទាន់ដឹងថាតើនៅក្នុងនីតិវិធីទាំងមូលប្រព្រឹត្តឡើងដោយដំណាក់កាលអ្វីខ្លះនោះទេ។ តាមរយៈគោលការណ៍នៃនីតិវិធីរដ្ឋប្បវេណី គេបានបែងចែកជាដំណាក់ធំៗ ដូចជា៖ ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការចេញសាលក្រម។ នៅក្នុងចំណោម នីតិវិធីទាំងនោះ មាននីតិវិធីមួយដែលភាគច្រើនពុំសូវមានសាមញ្ញជន ក្រៅពីអ្នកសិក្សាអំពីច្បាប់ យល់ថាតើវាជាអ្វីនោះ គឺ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយលម្អិតក្នុងសារណាមួយនេះ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ជានីតិវិធីដ៏ចាំបាច់មួយដែលផ្តល់ភាពងាយស្រួលក្នុងនីតិវិធីបន្តទៅទៀត ដែលមានបញ្ញត្តិក្នុងគន្លី២ មាត្រា១០៣ ដល់មាត្រា១១២ក្នុងក្រមនីតិវិធីរដ្ឋ-ប្បវេណីក្នុងឆ្នាំ២០០៦។ នីតិវិធីមួយនេះបានសម្រួលដល់ការស្វែងរកចំនុចវិវាទ និងបង្រួមអង្គហេតុសម្រាប់ធ្វើការអះអាងក្នុងការទាមទារនៅក្នុងនីតិវិធីបន្ទាប់។ ម្យ៉ាងវិញទៀត នៅក្នុងនីតិវិធីនេះ ក៏បានជួយដល់ការរៀបចំឯកសារ ក៏ដូចជាភស្តុតាងពាក់ព័ន្ធនៃបណ្តឹងរបស់ភាគី ទាំងចុងចម្លើយ និងដើម-ចោទ។ ជាពិសេស នៅក្នុងនីតិវិធីអាចឲ្យភាគីចំណេញពេលវេលាក្នុងការដោះស្រាយបណ្តឹង។ តើវាអាចធ្វើឡើងតាមរបៀបណា? ជាចម្លើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុ មានដំណាក់កាលនៃការផ្សះផ្សា ដែលក្នុងករណីភាគីយល់ព្រមសម្របសម្រួល ឬឯកភាពទៅលើអង្គហេតុនោះ នីតិវិធីបន្តបន្ទាប់នឹងពុំកើតមានឡើងទៀតនោះទេ។

ដើម្បីដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន តើចាំបាច់ត្រូវចាប់ផ្តើមដំណើរការនៃនីតិវិធី សមត្ថកិច្ចរបស់តុលាការ សកម្មភាពរបស់ភាគីទាំងសងខាង និងបញ្ចប់នីតិវិធីយ៉ាងដូចម្តេច?

ការស្រាវជ្រាវនូវប្រធានបទសារណានេះគឺ ក្នុងគោលបំណងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍នូវវិស័យច្បាប់សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងដើម្បីចែករំលែកនូវនីតិវិធីមួយដែលពុំសូវមានអ្នកស្គាល់ច្រើន ហើយមានសារៈប្រយោជន៍ចំពោះការអនុវត្ត។ ជាងនេះទៅទៀតក៏ដើម្បីធ្វើជាឯកសារផ្សព្វផ្សាយមួយដែលផ្តល់តម្លៃសម្រាប់ការសិក្សា ក៏ដូចជាការយល់ដឹងពីបច្ចុប្បន្នភាពនៃការវិវត្តនៃវិស័យច្បាប់របស់កម្ពុជា។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវសារណាមួយនេះ ក្រុមយើងខ្ញុំបានបែងចែកជា៣ជំពូកធំៗដូចជា៖

**ជំពូកទី១៖ ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី២៖ សកម្មភាពរបស់តុលាការ និងភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី៣៖ ការបញ្ចប់ និងអានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ខ្លឹមសារនៃជំពូកនីមួយៗខាងលើនេះ នឹងបង្ហាញជូនទាំងស្រុងក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដូចខាងក្រោម។

# ជំពូកទី១៖ ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីនៃបណ្តឹងរដ្ឋប្បវេណីមានដំណាក់កាលជាច្រើន ដោយមានការចាប់ផ្តើមពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹង ការត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ និងការជំនុំជម្រះក្តី។ ក្រោយពីដើមបណ្តឹងបានដាក់ពាក្យបណ្តឹង ហើយតុលាការបានទទួលពាក្យបណ្តឹង នោះពាក្យបណ្តឹងនឹងត្រូវបញ្ជូនទៅចៅក្រមទទួលបន្ទុកដែលបានចាត់តាំងទុកជាមុន ដោយដីកាសម្រេចរបស់ប្រធានតុលាការដែលកំណត់ទុកជាមុនជារៀងរាល់ឆ្នាំ ដើម្បីធ្វើការពិនិត្យ និង បញ្ជូនពាក្យបណ្តឹងទៅភាគីម្ខាងទៀតនៃបណ្តឹង គឺចុងចម្លើយ។[1] បន្ទាប់មក តុលាការនឹងកំណត់កាលបរិច្ឆេទការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

នៅក្នុងដំណាក់ការនៃនីតិវិធីនេះទៀតសោត នឹងមានការសិក្សាទៅលើ ចំនុច២សំខាន់ ដែលរួមមាន ១.១. សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ១.២. អំឡុងពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចខាងក្រោម។

## ១.១. សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណី នីតិវិធីនៃការជំនុំជម្រះរឿងក្តីគឺផ្តោតសំខាន់ទៅលើនីតិវិធីចំនួន២ សំខាន់ៗ ដែលក្នុងនោះរួមមាន នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយឡែក ក្នុងការបកស្រាយខាងក្រោមនេះ គឺលើកយកតែនីតិវិធីទី១ យកមកធ្វើការពិព័ណនា និងអត្ថាធិប្បាយតែប៉ុណ្ណោះ ដែលនៅក្នុងអធិប្បាយសេចក្តីនេះមាន២ចំណុច គឺ ទី១ អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ទី២ អំឡុងពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

មុននឹងធ្វើការបកស្រាយលើចំនុច៤ខាងក្រោម ជាគោលការណ៍នៃនីតិវិធីរដ្ឋប្បវេណី គឺភាគីនៃបណ្តឹងមានសិទ្ធិទាមទារឲ្យតុលាការធ្វើការសាកសួរ ដើម្បីអាចមានឱកាសបញ្ចេញមតិផ្ទាល់ខ្លួនពាក់ព័ន្ធនឹងរឿងក្តី ហើយនឹងមានឱកាសនិយាយតទល់ចំពោះមុខដូចគ្នារវាងដើមចោទ និងចុងចម្លើយ។[2]

[1] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៦

[2] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា៣ ចែងអំពី សិទ្ធិទាមទារឲ្យសាកសួរ គោលការណ៍ចំពោះមុខ

ដូច្នេះ ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីឆ្លើយតបទៅនឹងគោលការណ៍ខាងលើនេះ ហើយក៏ដើម្បីជួយសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ផងដែរ។

### ១.១.១. និយមន័យ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុ-ផលដោយផ្ទាល់មាត់ ដើម្បីលើកកម្ពស់ និង សម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[3]

### ១.១.២. គោលបំណង

ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី យើងឃើញថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ-ហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំនុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើជាការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់។[4]

### ១.១.៣.គោលការណ៍ជាមូលដ្ឋាន

គោលការណ៍ជាមូលដ្ឋាន គឺជាគោលគំនិត ឆន្ទៈនយោបាយសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈចាប់បង្ខំ ចង្អុលបង្ហាញ និងសម្រេចតាមប្រព័ន្ធនៃបណ្តាបទបញ្ញាត្តិនៃនីតិវិធី និងស្តែងឡើងនូវលក្ខណៈនៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយផ្តើមចេញពីទស្សនៈឆន្ទៈរបស់រដ្ឋចំពោះស្ថានភាពសង្គមជាក់-ស្តែង បណ្តាបទដ្ឋានគតិយុត្តដែលមានតម្លៃខ្ពស់បំផុតគឺរដ្ឋធម្មនុញ្ញ ដែលជាបទដ្ឋានជាន់ខ្ពស់បំផុតដូច-ជាច្បាប់ចាត់តាំងតុលាការជាអាទិ៍ ច្បាប់ពាក់ព័ន្ធដទៃទៀត គោលនយោបាយឯកជន រួមទាំងតម្រូវការនិងការទាមទាររបស់សង្គមជាតិ និងអន្តរជាតិផងដែរ។ និយាយដោយឡែក គោលការណ៍ជាមូលដ្ឋានអាចចាត់ទុកជាគម្រោងឆ្អឹងនៃច្បាប់ ដែលទ្រទ្រង់ប្រព័ន្ធច្បាប់ទាំងមូលឲ្យមានជំហររឹងមាំ និងមានចលនារស់រវើកនៅពេលច្បាប់នោះត្រូវបានអនុវត្ត។

ក្រមនីតិវិធីរដ្ឋប្បវេណីពឹងផ្អែកលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ហើយដែលជាគោលការណ៍មូលដ្ឋាននៃនីតិរដ្ឋប្រជាធិបតេយ្យផងដែរ។

[3] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ភាគ១ ស្តីពីនីតិវិធីបណ្តឹង ឆ្នាំ២០០៨ ទំព័រ ៧៣

[4] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៣ ចែងអំពី គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.១.៣.១.គោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការ

អំណាចតុលាការជាអំណាចឯករាជ្យ[5] ហើយព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ[6]។ អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ[7]។ គោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការ ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ជាមូលដ្ឋាន មិនត្រឹមតែនៅក្នុងបទដ្ឋានគតិយុត្តជាតិតែប៉ុណ្ណោះទេ វាក៏ត្រូវបានទទួលស្គាល់ដោយបទដ្ឋានគតិយុត្តដែលមានលក្ខណៈជាសកលដែលអង្គការសហប្រជាជាតិបានអនុម័ត[8]។ គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី គឺការការពារសិទ្ធិរបស់បុគ្គលឯកជន តាមរយៈវិធានចាប់បង្ខំមួយដោយតុលាការ ដើម្បីដោះស្រាយនូវវិធានពាក់ព័ន្ធនឹងផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ ដើម្បីធានារក្សាអនាគតិ ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ស្របច្បាប់ របស់ប្រជាពលរដ្ឋ និងផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋបាននោះ ចៅក្រម ណាដែលជាអ្នកទទួលបាននូវអំណាចតុលាការ ត្រូវតែស្ថិតក្នុងស្ថានភាពមិនលំអៀង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងពុំទទួលនូវការជ្រៀតជ្រែក និងទទួលឥទ្ធិពលពីសំណាក់ស្ថាប័នរដ្ឋណាមួយ ឬ ពីសំណាក់ភាគីណាមួយនៃរឿងក្តីឡើយ។ ម្យ៉ាងទៀត ចៅក្រមត្រូវបានធានានូវឋានៈរបស់ខ្លួន ពោលគឺមិនអាចត្រូវបានគេដកពីតំណែងដោយសារលទ្ធផលនៃការបំពេញមុខងារជាចៅក្រមបានឡើយ លើកលែងតែចៅក្រមនោះ បានប្រព្រឹត្តបទល្មើស នោះទើបឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យទៅលើចៅក្រមនោះបាន។ ការធានាឯករាជ្យភាពនៃអំណាចតុលាការ ពោលគឺចៅក្រមនិងឋានៈរបស់ចៅក្រម គឺជាគោលការណ៍មូលដ្ឋានមួយនៅក្នុងក្រមនីតិវិធីរដ្ឋប្បណី។

### ១.១.៣.២.គោលការណ៍នៃការជម្រះក្តីតាមច្បាប់ (គោលការណ៍នីត្យានុកូល)

ច្បាប់ជាទូទៅ ដែលនៅក្នុងនោះរួមមានទាំងក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ ត្រូវបាន អនុម័តដោយសភា ដែលជាអ្នកតំណាងឲ្យពលរដ្ឋខ្មែរដែលជាម្ចាស់សិទ្ធិ។ ពិតមែនតែឯករាជ្យភាពរបស់ចៅក្រមត្រូវបានធានាដោយច្បាប់ ប៉ុន្តែពុំមានន័យថាចៅក្រមអាចយកអំណាចនេះមកប្រើប្រាស់ជាពិសេសនៅក្នុងការដោះស្រាយបណ្តឹងរដ្ឋប្បវេណីតាមតែទំនើងចិត្តរបស់ខ្លួនបាននោះទេ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់កថាខណ្ឌទី១ នៃមាត្រា១២៩ ថ្មី បានចែងច្បាស់ថា "ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិ និងច្បាប់ជាធរមាន" មានន័យថា ក្រមនីតិវិធីរដ្ឋប្បវេណី

---

[5] កថាខណ្ឌទី១ មាត្រា១២៨ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[6] កថាខណ្ឌទី២ មាត្រា១៣២ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[7] កថាខណ្ឌទី៣ មាត្រា១២៨ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[8] គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃក្រុមចៅក្រម ដែលអនុម័តដោយអង្គការសហប្រជាជាតិ

និងច្បាប់សារធាតុដែលជាមូលដ្ឋាននៃការជំនុំជម្រះក្តី ត្រូវតែបានអនុវត្តដោយតឹងរ៉ឹង និងត្រូវបានបក-ស្រាយដោយឯកភាពគ្នាបំផុត សម្រាប់ចៅក្រមគ្រប់រូបដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងរដ្ឋ-ប្បវេណី។ ដើម្បីឆ្លើយតបការទាមទារនៃរដ្ឋធម្មនុញ្ញនោះគោលការណ៍ នៃការជម្រះក្តីតាមច្បាប់ត្រូវបានទទួលស្គាល់ និងបញ្ញត្តិជាក់ស្តែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី[9]។

### ១.១.៣.៣.គោលការណ៍នៃការធានាសិទ្ធិពឹងពាក់តុលាការ

នៅក្នុងជីវភាពរស់នៅ នៅក្នុងសង្គម ជាពិសេសសង្គមសេដ្ឋកិច្ចផ្សារសេរី នោះបុគ្គលម្នាក់ៗ ធ្វើសកម្មភាពសេដ្ឋកិច្ចដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន តាមរយៈការគ្រប់គ្រងមធ្យោបាយផលិតកម្ម ការដោះដូរ និងសកម្មភាពសេវាផ្សេងៗទៀត ពោលគឺភាគច្រើនតាម រយៈកិច្ចសន្យារវាងមនុស្ស និងមនុស្ស។ ក្នុងនាមជាពលរដ្ឋនៃនីតិរដ្ឋប្រជាធិបតេយ្យមនុស្សត្រូវគោរពនូវការសន្យា ស្មោះត្រង់ និងសុចរិត ពោលគឺគោរពតាមអ្វីៗ ដែលច្បាប់បានកំណត់ និងវិធានផ្សេងទៀត ដូចជា សីលធម៌ សាសនា ទំនៀមទម្លាប់ ប្រពៃណីជាអាទិ៍។ ប៉ុន្តែបាតុភូតដែលកើតឡើងនៅក្នុងទំនាក់ទំនងសង្គមនេះ មិនមែនសុទ្ធតែមានលក្ខណៈវិជ្ជមានដូចដែលប៉ងប្រាថ្នានោះឡើយ ដូចនេះទំនាស់បានកើតមានឡើង ហើយទំនាស់ទាំងនោះត្រូវតែនាំយកទៅដោះស្រាយដោយវិធានផ្សេងៗគ្នា តាមតែភាគីមានទំនាស់ចង់បាន ដើម្បីឈានទៅរកលទ្ធផលដែលអាចទទួលយកបាន។ នៅពេលដែលវិធាននៃការដោះស្រាយវិវាទដោយខ្លួនឯង និង អាចទទួលយកបានពីសំណាក់សង្គមដូចជាការសះជា ឬតាមផ្លូវមជ្ឈតករ ឬសន្ធាន-កម្មពុំទទួលបានលទ្ធផលនោះ ភាគីទំនាស់ ជាពិសេសភាគីដែលយល់ថាសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនត្រូវបានបំពាន មានសេរីភាព និងសិទ្ធិជ្រើសរើសយកយកវិធាននៃការដោះស្រាយទំនាស់តាមផ្លូវតុលាការដែលជាវិធានដោះស្រាយដោយបង្ខំបាន។ ដូចនេះ សិទ្ធិពឹងពាក់តុលាការ គឺជាសិទ្ធិរបស់ពលរដ្ឋតែមិនមែនជាអំណោយរបស់រដ្ឋ ដែលផ្តល់ឲ្យបុគ្គលឯកជននោះឡើយ។ យោងតាមទស្សនៈរបស់រដ្ឋដែលប្រកបដោយប្រជាធិបតេយ្យនោះការការពារសិទ្ធិរបស់បុគ្គលឯកជន គឺជាកាតព្វកិច្ចរបស់រដ្ឋ ឯពលរដ្ឋវិញនៅក្នុងករណីដែលសិទ្ធិរបស់ខ្លួនត្រូវបានបំពាន នោះបុគ្គលនេះមានសិទ្ធិទទួលយកការជម្រះក្តីរបស់តុលាការ ដើម្បីទទួលបានការការពារសិទ្ធិពីរដ្ឋតាមរយៈការដាក់ពាក្យប្តឹងទៅតុលាការ។

[9] មាត្រា២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

### ១.១.៣.៤.គោលការណ៍នៃការធានាសិទ្ធិទាមទារឲ្យសាកសួរនិងសវនាការ

ជាការពិត បណ្ដឹងរដ្ឋប្បវេណីធ្វើឡើងក្នុងគោលបំណងឲ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ការធានានូវសិទ្ធិពឹងពាក់តុលាការក៏ជាការទាមទារមួយព្រមគ្នានូវនីតិវិធីដោះស្រាយ និង សម្រេចសេចក្ដីមួយប្រកបដោយយុត្តិធម៌។ សេចក្ដីសម្រេចរបស់តុលាការមានលក្ខណៈចាប់បង្ខំឲ្យភាគីទទួលយកនៅពេល ដែលសេចក្ដីសម្រេចនោះមានអានុភាព ពោលគឺ ភាគីនៃបណ្ដឹងរដ្ឋប្បវេណី ទទួលឥទ្ធិពលដល់សិទ្ធិរបស់ខ្លួនដោយសេចក្ដីសម្រេចរបស់តុលាការ ដូចនេះភាគីត្រូវមានឱកាសដើម្បីបានបញ្ចេញមតិរបស់ខ្លួនចំពោះចំណុចដែលត្រូវវិនិច្ឆ័យដោយតុលាការ និងឆ្លើយតបចំពោះមតិដែលបញ្ចេញដោយភាគីម្ខាងទៀត មុនពេលមានការសម្រេចសេចក្ដី។ ការធានាសិទ្ធិទាមទារឲ្យសាកសួរជាគោលការណ៍មូលដ្ឋានមួយនៃប្រព័ន្ធនីតិវិធីបណ្ដឹងនៅក្នុងរដ្ឋប្រជាធិបតេយ្យសម័យទំនើបបានប្រកាន់យកតាមប្រព័ន្ធច្បាប់នៃបណ្ដាប្រទេសមួយចំនួនដូចជាច្បាប់មូលដ្ឋាន នៃប្រទេសអាឡឺម៉ង់ និងក្រមរដ្ឋប្បវេណីនៃប្រទេសបារាំងជាដើម[10]។

មានករណីពិសេសខ្លះនោះ គោលការណ៍ធានាសិទ្ធិទាមទារឲ្យសាកសួរត្រូវបានលើកលែងដោយការទាមទារឲ្យដោះស្រាយដោយឆាប់រហ័សនូវបញ្ហាមួយចំនួន ដែលអនុញ្ញាតឲ្យតុលាការធ្វើការសម្រេចសេចក្ដីជាមុន រួចហើយទើបសាកសួរភាគីដែលអាចទទួលរងនូវការខូចខាតដោយការសម្រេចសេចក្ដីនោះនៅពេលក្រោយ ដូចជាការសម្រេចសេចក្ដីតាមរូបភាពជាដីកាសម្រេចដាស់តឿន[11] ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[12] ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន[13]ជាអាទិ៍។

ដូចគ្នានេះផងដែរ ការធានាសិទ្ធិសវនការ គឺជាសិទ្ធិមួយជាមូលដ្ឋានរបស់ភាគីដែលត្រូវបានទទួលស្គាល់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ហើយដែលជាឱកាសដែលអាចផ្ដល់ឲ្យភាគីបានបញ្ចេញមតិរបស់ខ្លួន និង ឆ្លើយតបទៅនឹងមតិរបស់ភាគីម្ខាងទៀតនៅមុនពេល ដែលតុលាការឈានដល់ការសម្រេចជាចុងក្រោយចំពោះការទាមទាររបស់ភាគីណាមួយ។

---

[10] កថាខណ្ឌទី១ មាត្រា១០៣ច្បាប់មូលដ្ឋាន(រដ្ឋធម្មនុញ្ញ)អាឡឺម៉ង់និងមាត្រា១៤ ក្រមនីតិវិធីរដ្ឋប្បវេណីបារាំង

[11] មាត្រា៣២៣ក្រមនីតិវិធីរដ្ឋប្បវេណី

[12] មាត្រា៥៤៥ ក្រមនីតិវិធីរដ្ឋប្បវេណី

[13] មាត្រា៥៣៨ ក្រមនីតិវិធីរដ្ឋប្បវេណី

### ១.១.៣.៥.គោលការណ៍ចំពោះមុខ

សិទ្ធិទាមទារមានប្រសិទ្ធិភាព នៅពេលដែលភាគីទាំងសងខាងបានបង្ហាញនៅកាលបរិច្ឆេទតែមួយ ហើយធ្វើការវិនិច្ឆ័យទៅលើអង្គហេតុដោយវិធីតតាំងនៅចំពោះមុខគ្នាទៅវិញទៅមក។ ម៉្យាងទៀត ប្រសិនបើអនុញ្ញាតឲ្យតុលាការកោះហៅភាគីម្ខាងទៀតមកសាកសួរនៅកាលបរិច្ឆេទមួយ ឬនៅកន្លែងណាមួយដែលភាគីម្ខាងអវត្តមាន នោះនឹងនាំឲ្យមានការបាត់បង់នូវជំនឿទុកចិត្ត ចំពោះភាពយុត្តិធម៌នៃការវិនិច្ឆ័យសេចក្តីរបស់តុលាការទៀតផង។ គោលការណ៍ចំពោះមុខត្រូវបានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណីក្នុងគោលបំណងធានានូវភាពយុត្តិធម៌ និងទំនុកចិត្តរបស់ភាគី ក៏ដូចជាពលរដ្ឋទូទៅចំពោះប្រព័ន្ធដោះស្រាយនីតិវិធីនៃបណ្តឹង។ ទោះបីបែបនេះក៏ដោយក៏មានករណីលើកលែងខ្លះ ត្រូវបានទទួលស្គាល់ថាជាករណីពិសេសផងដែរ ដូចជាករណីដែលសម្រេចសេចក្តីដោយសាលក្រមកំបាំងមុខដើមចោទ[14] សាលក្រមកំបាំងមុខចុងចម្លើយ[15] ការចេញដីកាសម្រេចដាស់តឿនជាអាទិ៍[16]។

### ១.១.៣.៦.គោលការណ៍នៃការទទួលខុសត្រូវរបស់តុលាការ និងភាគី

តុលាការត្រូវប្រឹងប្រែងដើម្បីធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឲ្យប្រព្រឹត្តទៅដោយយុត្តិធម៌ និង ឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និង ស្មោះត្រង់[17]។

ក្នុងនាមជាអ្នកអនុវត្តនីតិវិធី តុលាការត្រូវប្រឹងប្រែង និង គប្បីជៀសវាងនូវការប្រើពាក្យសម្តី ឬអំពើណាដែលនាំឲ្យមានការសង្ស័យអំពីភាពយុត្តិធម៌។ "យុត្តិធម៌យឺតយ៉ាវ ស្មើនឹងការបដិសេធនូវយុត្តិធម៌" ជាពាក្យសុភាសិតច្បាប់ដែលត្រូវបានទទួលស្គាល់ជាសកល ដូចនេះតុលាការមិនត្រឹមតែត្រូវប្រឹងប្រែងដោះស្រាយបណ្តឹង និងដឹកនាំនីតិវិធីនៃបណ្តឹងឲ្យប្រព្រឹត្តទៅដោយយុត្តិធម៌ប៉ុណ្ណោះទេ គឺថែមទាំងព្យាយាមអនុវត្តច្បាប់ស្តីពីនីតិវិធី ដោយឆាប់រហ័សទៀតផងនោះទើបជាការដោះស្រាយដោយយុត្តិធម៌ពិតៗ។

យុត្តិធម៌ និង គោលដៅរហ័សជាគោលការណ៍ពីរ ដែលជាការទទួលខុសត្រូវរបស់តុលាការ ដូចនេះទាមទារឲ្យតុលាការមានការចុះសម្រុងគ្នា រវាងភាពឆាប់រហ័សនៃការអនុវត្តនីតិវិធី និងការទាមទារឲ្យមានភាពត្រឹមត្រូវនៃការសម្រេចសេចក្តី។

---

[14] មាត្រា២០០ ក្រមនីតិវិធីរដ្ឋប្បវេណី

[15] មាត្រា២០០ ក្រមនីតិវិធីរដ្ឋប្បវេណី

[16] មាត្រា៣២៣ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

[17] មាត្រា៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅក្នុងរបបបណ្តឹងរដ្ឋប្បវេណី ភាគីត្រូវទទួលស្គាល់ថាមានសេរីភាព និងមានសិទ្ធិចាត់ចែងបណ្តឹងរដ្ឋប្បវេណី ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ពោលគឺការទទួលបាននូវសាលក្រមដែលសម្រេចឲ្យខ្លួនឈ្នះក្តី។ ប៉ុន្តែ ភាគីមិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពដោយទុច្ចរិត និង មិនស្មោះត្រង់ចំពោះភាគីម្ខាងទៀតឡើយ។ សកម្មភាពដែលផ្ទុយនឹងភាពសុច្ចរិត ស្មោះត្រង់ ត្រូវបានវិនិច្ឆ័យទៅតាមករណីជាក់ស្តែងនីមួយៗ និង យោងទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបញ្ញត្តិនិងចាត់ថាសកម្មភាពមួយចំនួនរបស់ភាគីគឺជាសកម្មភាពផ្ទុយនឹងភាពសុច្ចរិត ស្មោះត្រង់ ហើយដែលលទ្ធផលរបស់សកម្មភាពទាំងនោះនឹងនាំមកនូវការខូចខាតប្រយោជន៍របស់ភាគី ដែលបានធ្វើសកម្មភាពមិនត្រឹមត្រូវ[18]។

### ១.១.៣.៧.ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិទាមទារឲ្យមានការបកប្រែភាសារបស់ភាគី

"ភាសា និង អក្សរដែលប្រើជាផ្លូវការគឺភាសាខ្មែរ និង អក្សរខ្មែរ" គឺបញ្ញត្តិមូលដ្ឋានដែលត្រូវបានចែងនៅក្នុងមាត្រា៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងនាមជារដ្ឋមួយប្រកបដោយអធិបតេយ្យភាព ឯករាជ្យ និង មិនអាចបំបែកបាន នោះព្រះរាជាណាចក្រកម្ពុជាមានភាសា និងអក្សរជាតិរបស់ខ្លួន គឺភាសា និង អក្សរខ្មែរ ដែលត្រូវបានប្រើប្រាស់ជាផ្លូវការនៅក្នុងសកម្មភាពគ្រប់គ្រងរដ្ឋ។ តុលាការជាស្ថាប័នមួយ ដែលទទួលអនុវត្តមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋពោលគឺ អំណាចតុលាការ ដូចនេះភាសាដែលប្រើក្នុងតុលាការ ត្រូវតែជាភាសាខ្មែរ។ ក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិយកជាភាសាខ្មែរជាភាសាដែលត្រូវប្រើប្រាស់ក្នុងតុលាការ[19]។

ភាគីដែលមិនអាចយល់ជាភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែដែលខ្លួនអាចយល់បាន។ សិទ្ធិទាមទារឲ្យសាកសួរសវនការ និង គោលការណ៍ចំពោះមុខ ព្រមទាំងភាពយុត្តិធម៌ក្នុងការសម្រេចសេចក្តីនឹងមិនត្រូវបានធានាឡើយ ប្រសិនបើភាគីណាមួយពុំអាចយល់បានអំពីបញ្ហា ដែលត្រូវបានលើកឡើងដោយភាគីម្ខាងទៀត ឬដោយតុលាការ ប្រសិនបើគេមិនអាចយល់ជាភាសាខ្មែរ ដូចនេះសិទ្ធិទាមទារឲ្យមានការបកប្រែភាសារបស់ភាគី ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ជាមូលដ្ឋានមួយ ក្នុងចំណោម

---

[18] សកម្មភាពដែលនីតិវិធីរដ្ឋប្បវេណីចាត់ទុកថាផ្ទុយនឹងភាពសុច្ចរិត ស្មោះត្រង់ដូចជា "ការលើកចោលមធ្យោបាយតទល់ ឬការការពារខ្លួនដែលបានដាក់ដោយយឺតយ៉ាវ(មាត្រា៩៨)អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(មាត្រា១០៨)អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារជាអាទិ៍(មាត្រា១៥៣)

[19] មាត្រា៥ក្រមនីតិវិធីរដ្ឋប្បវេណី

គោលការណ៍ជាមូលដ្ឋានផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយបញ្ហារកអ្នកបកប្រែគឺជាបន្ទុករបស់រដ្ឋនៅក្នុងករណីដែលភាគីមិនមានលទ្ធភាពរកអ្នកបកប្រែដោយខ្លួនឯងបាន។

### ១.១.៣.៨.ការចូលរួមរបស់តំណាងអយ្យការ

ជាគោលការណ៍តំណាងអយ្យការគឺ ជាអ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ ហេតុនេះ ប្រសិនបើមានការចាំបាច់ សម្រាប់ការការពារផលប្រយោជន៍សាធារណៈ នោះតំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បាន តាមការយល់ឃើញរបស់ខ្លួន ឬតាមការជូនដំណឹងរបស់តុលាការបាន។ ទស្សនៈតំណាងអយ្យការជាអ្នកតំណាងឲ្យផលប្រយោជន៍សាធា-រណៈ មិនមានន័យថាតំណាងអយ្យការចូលរួមក្នុងនីតិវិធីនៃបណ្តឹងក្នុងនាមជាខ្លួនជាភាគីនៃបណ្តឹងនោះឡើយ។ ទស្សនៈនេះផ្ទុយគ្នាផងដែរជាមួយ ទស្សនៈដែលធ្លាប់មានពីមុនមក ដែលថាតំណាងអយ្យការជាអ្នកតំណាងដោយអាណត្តិនៅក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលភាគីជាអនីតិ-ជនជាដើម។ អ្នកដែលត្រូវការពារផលប្រយោជន៍របស់អនីតិជនគឺជាអ្នកតំណាងដែលច្បាប់បានកំណត់ដូចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលក្នុងករណីដែលគ្មានអ្នកមានអំណាចមេបា ប៉ុន្តែ មិនមែនជាតំណាងអយ្យការឡើយ។

## ១.១.៤. សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីផ្តល់សមភាព និងភាពយុត្តិធម៌ដល់ភាគីនៃវិវាទ តាមរយៈការជួបគ្នាផ្ទាល់នៅក្នុងពេលតែមួយ និងកន្លែងតែមួយ ដើម្បីធ្វើការអះអាងអំពីអង្គហេតុ និងការដាក់ភស្តុតាងជូនតុលាការ។ មួយវិញទៀត នីតិវិធីនេះអាចធ្វើការជម្រះក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មិនមានភាពស្មុគស្មាញ ពីព្រោះតុលាការអាចស្នើឲ្យភាគីដកការអះអាងអំពីអង្គហេតុណាដែលមិនមានសារៈប្រយោជន៍ចំពោះការសម្រេចសេចក្តី និងអាចផាត់-ចោលនូវអង្គហេតុណាដែលភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។ ការណ៍ដែលនាំឲ្យមានភាពស្មុគស្មាញគឺថា នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុ ផ្សេងៗដែលខ្លួនយល់ថាមានសារៈប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំគិតថាអង្គហេតុទាំងនោះ មាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ។ ស្របពេលជាមួយគ្នានេះផងដែរ ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ក៏ប៉ុន្តែ ការធ្វើ

បែបនេះនឹងនាំឲ្យការជម្រះក្តីមានភាពស្មុគស្មាញ និង អូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឲ្យមានការលំបាកក្នុងការស្វែងរកការពិត។[20] ជាងនេះទៅទៀត តុលាការអាចចម្រាញ់យកតែភស្តុតាងណាដែលសំខាន់ និង មានតម្លៃសម្រាប់អង្គហេតុតែប៉ុណ្ណោះ។[21]

ដោយហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន។

## ១.២. អំឡុងពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវដំណើរការទៅនាពេលវេលាមួយដែលកំណត់ដោយតុលាការ និងស្ថិតនៅក្រោមការដឹកនាំរបស់បុគ្គលដែលច្បាប់បានផ្តល់សិទ្ធិឲ្យ។ ច្បាប់ពុំបានកំណត់ថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ អាចធ្វើឡើងបានប៉ុន្មានដងនោះទេ ដូច្នេះនីតិវិធីនេះ អាចធ្វើឡើងច្រើនដំណាក់កាលបាន គឺអាស្រ័យទៅតាមសភាពនៃរឿងក្តី បើរឿងក្តីមានលក្ខណៈស្មុគស្មាញ នោះតុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះច្រើនលើកច្រើនសារបាន។ ផ្ទុយទៅវិញ ប្រសិនបើរឿងក្តីដែលមានលក្ខណៈងាយស្រួល នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ អាចធ្វើតែម្តងហើយចប់ក៏បានដែរ ឲ្យតែតុលាការអាចកំណត់បាននូវចំណុចវិវាទនៃរឿងក្តី។

### ១.២.១. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីកុំឲ្យមានការយឺតយ៉ាវក្នុងដំណើរការនីតិវិធី និងដើម្បីឲ្យភាគីចុងចម្លើយមានពេលសមរម្យអាចត្រៀមលក្ខណៈការពារខ្លួនបាន ដូច្នេះច្បាប់តម្រូវឲ្យកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង។[22] កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកំណត់ដោយឆន្ទានុសិទ្ធិរបស់តុលាការ ឬ អាចត្រូវបានកំណត់តាមពាក្យសុំរបស់ភាគីទាំងសងខាងផងដែរ។[23] ជាគោលការណ៍ភាគីពុំអនុញ្ញាតឲ្យធ្វើការផ្លាស់

[20] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ភាគ១ ស្តីពីនីតិវិធីបណ្តឹង ឆ្នាំ២០០៨ ទំព័រ ៧៤
[21] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៧ ចែងអំពី ការពិនិត្យភស្តុតាងដោយសមូហវិធី
[22] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា៨០ កថាខណ្ឌទី២
[23] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨០ កថាខណ្ឌទី១

ប្តូរកាលបរិច្ឆេទទេ ប្រសិនបើគ្មានមូលហេតុដែលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរកាលបរិច្ឆេទនោះ។[24] ករណីលើកលែងចំពោះកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង អាចផ្លាស់ប្តូរបានប្រសិនបើមានការព្រមព្រៀងពីសំណាក់គូរភាគីទាំងសងខាង។[25]

បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ តុលាការត្រូវចេញដីកាកោះហៅភាគីដើម្បីឲ្យចូលរួមក្នុងនីតិវិធី ឬ អាចប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទទៅអ្នកដែលពាក់ព័ន្ធនឹងបណ្តឹង ដែលបានបង្ហាញខ្លួននៅតុលាការ។[26]

ដើម្បីឲ្យស្របទៅនឹងគោលការណ៍ចំពោះមុខ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។[27] ប៉ុន្តែប្រសិនបើភាគីណាម្ខាងអវត្តមាននៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏តុលាការអាចធ្វើនីតិវិធីនេះដោយស្របច្បាប់បានដែរ។ បន្ថែមពីនេះ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ[28] នេះគឺដោយសារតែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំនុចវិវាទ តាមរយៈការអះអាងរបស់ភាគី និង គ្រាន់តែរៀបចំនូវភស្តុតាងដែលត្រូវត្រួតពិនិត្យតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងក៏ដោយ តុលាការអាចអនុញ្ញាតឲ្យជនដែលខ្លួនយល់ឃើញថាសមរម្យ ដូចជាសមាជិកគ្រួសាររបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀត ចូលស្តាប់ជាអ្នកអង្កេតការណ៍បាន។[29] ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យអ្នកអង្កេត-ការណ៍ចូលស្តាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ។ នៅពេលធ្វើសេចក្តីសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតនេះ តុលាការត្រូវពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្តាប់ ព្រមទាំងមតិរបស់ភាគីផងដែរ។ ក្នុងករណីដែលការស្នើសុំចូលស្តាប់ ត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការពាក់ព័ន្ធទៅនឹងរឿងក្តី ជាគោលការណ៍ តុលាការអាចផ្តល់ការអនុញ្ញាតចំពោះការស្នើសុំនោះបាន ប្រសិនបើការចូលស្តាប់នោះ មិនទំនងជានឹងបង្កបញ្ហាដល់ការជម្រះក្តីទេ។ ប៉ុន្តែក្នុងករណីដែលយល់ឃើញថា ភាគីណា

[24]ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨១ កថាខណ្ឌទី១
[25] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨១ កថាខណ្ឌទី៣
[26] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨២
[27] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥
[28] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១
[29] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២

ម្ខាងអាចរងការប៉ះពាល់ផ្លូវចិត្តដោយសារតែវត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនោះ តុលាការមិនអនុញ្ញាតឲ្យបុគ្គលនោះចូលស្តាប់ទេ។

សកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះត្រូវបានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់នាពេលក្រោយ និងត្រូវបំភ្លឺអំពីបញ្ហាទាំងអស់នេះ នៅក្នុងសវនាការជាសាធារណៈ។[30]

### ១.២.២. ការធ្វើកំណត់ហេតុ

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពជាច្រើនដែលត្រូវបានធ្វើដោយចៅក្រម ភាគី ឬអ្នកតំណាង ហើយសកម្មភាពនេះមិនអាចបញ្ជាក់បានទេ ប្រសិនបើពុំមានការកត់ត្រា។ មួយវិញទៀត កំណត់ហេតុនេះមានសារៈសំខាន់ណាស់សម្រាប់តុលាការជាន់ខ្ពស់ក្នុងការពិនិត្យលើចំណាត់ការរបស់តុលាការ ដែលបានធ្វើកំណត់ហេតុនោះ។

#### ១.២.២.១. អ្នកធ្វើកំណត់ហេតុ

មួយវិញទៀត កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅគ្រប់កាលបរិច្ឆេទនីមួយៗ[31] ដូចនេះអ្នកដែលមានតួនាទីធ្វើកំណត់ហេតុគឺក្រឡាបញ្ជី ដែលជាអ្នកមានសមត្ថកិច្ច។

#### ១.២.២.២. ទម្រង់កំណត់ហេតុ

ទម្រង់កំណត់ហេតុត្រូវបានរៀបចំជាចំណុចជារូបមន្តដែលរួមមានៈ

- សញ្ញាណនៃរឿងក្តី
- ឈ្មោះចៅក្រម និងក្រឡាបញ្ជី
- ឈ្មោះភាគី អ្នកតំណាងអ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន
- ពេលវេលា និងទីកន្លែង ហើយចៅក្រម និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ[32]។

[30] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី១

[31] មាត្រា១០៩ ក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងកំណត់ហេតុក៏ត្រូវសរសេរអំពីចំណុចជាសារធាតុដែលជាចំណុចសំខាន់រួមមានៈ[33]

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញនិងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឲ្យពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគីម្ខាងទៀត និងការទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ
- ចំណុចដែលតុលាការបង្គាប់ឲ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឲ្យកត់ត្រាតាមការទាមទាររបស់ភាគី និង
- ដោយសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។

### ១.២.៣. សមត្ថកិច្ចដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណីការជម្រះក្តីដោយចៅក្រមតែម្នាក់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវស្ថិតក្រោមការដឹកនាំរបស់ចៅក្រមនោះផ្ទាល់។ ប៉ុន្តែប្រសិនបើ ការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះវិញនោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានក្រុមប្រឹក្សាជំនុំ-ជម្រះ ដោយអនុវត្តសិទ្ធិដឹកនាំនីតិវិធីក្នុងនាមជាក្រុមប្រឹក្សា។ ម្យ៉ាងទៀត ដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងដំណើរការដឹកនាំនីតិវិធី ចៅក្រម ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឲ្យជនណាម្នាក់មានសិទ្ធិនិយាយ និង ហាមមិនឲ្យជនណាម្នាក់និយាយបាន។[34] នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកជំនុំ-ជម្រះដោយចៅក្រមម្នាក់។[35] ប៉ុន្តែមានករណីមួយចំនួនទៀតដែលការជំនុំជម្រះមានការដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដូចជាៈ [36]

[32] មាត្រា១១០ ក្រមនីតិវិធីរដ្ឋប្បវេណី

[33] មាត្រា១១១ ក្រមនីតិវិធីរដ្ឋប្បវេណី

[34] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៩ កថាខណ្ឌទី២

[35] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី១

[36] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី២

- រឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹងមិនតិចជាង ៥លានរៀល
- រឿងក្តីដែលច្បាប់បានកំណត់ថាត្រូវវិនិច្ឆ័យ និង ជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលមានចៅក្រមចំនួន៣រូប។

### ១.២.៤. ទីតាំងសម្រាប់ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ទីតាំងច្បាស់លាស់សម្រាប់ធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះទេ។ ម៉្យាងទៀតនីតិវិធីនេះមិនចាំបាច់ធ្វើសាលសវនាការទេ ហើយតុលាការមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យនរណាម្នាក់ចូលស្តាប់នៅពេលធ្វើនីតិវិធី-ត្រៀមសម្រាប់ការទាញហេតុផលនេះបាន។ សព្វថ្ងៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលធ្វើនៅបន្ទប់ផ្ទាល់របស់ចៅក្រម ឬ បន្ទប់ផ្ទាល់របស់ក្រុមប្រឹក្សាជំនុំជម្រះតែម្តង។[37]

[37] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី២

## ជំពូកទី២៖ សកម្មភាពនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីបានបកស្រាយទៅលើបទបញ្ញត្តិទូទៅ និងអំឡុងពេលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលខាងលើរួចមក នៅចំនុចបន្តទៅនេះ នឹងមានការបកស្រាយទៅលើសកម្មភាពនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមាន២ផ្នែកធំៗដូចជា: ២.១. សកម្មភាពរបស់តុលាការ ២.២. សកម្មភាពរបស់ភាគី និង ដីកាសម្រេច និង ២.៣. កាលបរិច្ឆេទសម្រាប់ទាញហេតុផលក្រោយៗទៀត ដូចខាងក្រោម។

### ២.១. សកម្មភាពរបស់តុលាការ

នៅក្នុងដំណើរការនៃនីតិវិធីរឿងក្តីរដ្ឋប្បវេណី តុលាការមានតួនាទីយ៉ាងសកម្ម ដែលក្នុងនោះតុលាការត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួន ដូចជា ២.១.១. ការផ្សះផ្សា ២.១.២ ការត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ២.១.៣. ដីកាសម្រេចដែលមិនមែនជាសាលក្រម និង ២.១.៤. ការស្នើសុំផ្ទេរសមត្ថកិច្ចតាមឆន្ទានុសិទ្ធិតុលាការ ដែលមានការបកស្រាយ និងលើកជាឧទាហរណ៍ដូចខាងក្រោម។

#### ២.១.១ ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងរឿងក្តីរដ្ឋប្បវេណី ចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែងតែមានការសាកល្បងការផ្សះផ្សារវាងភាគីនៃបណ្តឹងទាំងពីរជាមុនសិន។ ប៉ុន្តែការសាកល្បងការផ្សះផ្សានេះមិនសុទ្ធតែត្រូវបានធ្វើឡើងនោះទេ គឺលើកលែងតែករណីដែលតុលាការយល់ឃើញថាសមរម្យ។[38] ម្យ៉ាងវិញទៀតតុលាការអាចធ្វើការផ្សះផ្សាបានទោះបីជាស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។[39]

"គោលការណ៍នៃការផ្សះផ្សាជាមុនដាច់ខាត" ត្រូវបានជំនួសដោយ "គោលការណ៍នៃការផ្សះផ្សាដែលមានលក្ខណៈមិនដាច់ខាត" វិញ។

ទោះបីជានីតិវិធីត្រូវបានធ្វើឡើងដោយសារការដាក់ពាក្យបណ្តឹងរបស់ដើមចោទ ប៉ុន្តែការចាត់ចែងជាសិទ្ធិរបស់ភាគី ហើយការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ក៏

[38] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៤
[39] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៧

អាចចាត់ចែងតាមរយៈការព្រមព្រៀងរវាងភាគីទាំងពីរបានផងដែរ។ ដូចនេះ ប្រសិនបើមានការសះជារវាងភាគី នោះវិវាទនឹងត្រូវបានបញ្ចប់។ ដោយមូលហេតុនេះ សាមគ្គីភាព និងភាពសុខសាន្តរបស់ភាគីក៏កើតមានឡើងស្របពេលនេះផងដែរ។ ប៉ុន្តែមានករណីខ្លះវិញ វិវាទមិនអាចបញ្ចប់ទៅបានដោយសារតែការព្រមព្រៀងរបស់ភាគីនោះទេ ពោលគឺសិទ្ធិចាត់ចែងរបស់ភាគីតាមឆន្ទៈត្រូវបានកម្រិតអាស្រ័យទៅតាមផលប្រយោជន៍ទូទៅរបស់សង្គម ឬ សណ្តាប់ធ្នាប់សាធារណៈ ឬ សកម្មភាពចាត់ចែងនោះសង្គមទទួលយកបាន ឬ ករណីដែលគ្មានសង្ឃឹមថាភាគីនិងព្រមព្រៀងគ្នានោះទេ តុលាការមិនត្រូវផ្សះផ្សា ឬមិនត្រូវធ្វើការផ្សះផ្សាឡើយ ។ យោងតាមស្ថានភាពនីមួយៗ ប្រសិនបើយើងឃើញថាការផ្សះផ្សាទទួលបានលទ្ធផល ឬ គប្បីធ្វើការផ្សះផ្សានោះ ជាគោលការណ៍តុលាការត្រូវធ្វើការផ្សះផ្សាដោយមានវត្តមានរបស់ភាគី នៅចំពោះមុខភាគីម្ខាងទៀតដែលស្របតាមគោលការណ៍នៃការផ្សះផ្សាក្នុងនីតិវិធីរដ្ឋប្បវេណីកម្ពុជា។ នៅក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់របស់ភាគី នោះតុលាការអាចធ្វើការសម្ភាសន៍តែចំពោះភាគីម្ខាង ឬ ម្តងម្នាក់ៗបាន ។

### ២.១.២.ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការ

#### ២.១.២.១. ពាក្យស្នើសុំលើអង្គសេចក្តីនៃរឿងក្តី

ការផ្សះផ្សាអាចធ្វើឡើងដោយជោគជ័យ និង បរាជ័យ។ ក្នុងករណីដែលការសាកល្បងការផ្សះផ្សារបស់តុលាការចំពោះភាគីទាំងពីរមិនបានសម្រេចទេនោះ តុលាការត្រូវចាប់ផ្តើមការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញ-ហេតុផលមានគោលបំណងធ្វើការរៀបចំនូវការអះអាងរបស់ភាគី ធ្វើការកំណត់នូវចំណុចវិវាទ និង ធ្វើការរៀបចំនូវភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងនីតិវិធីនេះ តុលាការត្រូវបង្គាប់ឲ្យភាគីដាក់ជាមុននូវការអះអាង និងភស្តុតាងដែលពួកគេមានបំណងនឹងដាក់នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

#### ២.១.២.២. ការបញ្ជាក់ចំណុចវិវាទ

នៅពេលភាគីបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនរួចមក ពេលនោះតុលាការត្រូវអនុវត្តសិទ្ធិឲ្យបំភ្លឺ និងរៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួននោះ ជាពិសេស ត្រូវរៀបចំការអះអាងរបស់ភាគីទាំងសងខាង ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាង

(ការរៀបចំភស្តុតាង នឹងត្រូវធ្វើការបកស្រាយនៅចំណុច ២.១.២.៣. ខាងក្រោម) ពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ នេះជាផ្នែកដ៏សំខាន់បំផុតនៃការជម្រះក្តីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[40]

ដូច្នេះ អ្វីទៅគឺជាចំណុចវិវាទនៅក្នុងរឿងក្តី?

ជាចម្លើយ ជាទូទៅ ចំណុចទាំងឡាយណាដែលភាគីទាំងសងខាងប្រកែកគ្នា (ជាធម្មតា គឺអង្គហេតុ) គេហៅថា ចំណុចវិវាទ។ ក្នុងករណីដែលភាគីណាម្ខាង បានអះអាងអំពី អត្ថិភាពនៃអង្គ-ហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀតជាបួនប្រភេទ ដូចខាងក្រោម៖

- *ទី១៖* ភាគីម្ខាងទៀតនោះអាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ដែលការធ្វើបែបនោះ គេហៅថា **ការបដិសេធ** (ការមិនទទួលស្គាល់)
- *ទី២៖* ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនេះ ដែលគេហៅថា **ការសារភាព**[41]
- *ទី៣៖* ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ថាខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការធ្វើបែបនេះ គេហៅថា **សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង**
- *ទី៤៖* ចុងក្រោយគេ គឺករណីដែលភាគីនោះមិនឆ្លើយអ្វីទាំងអស់។

ករណីទាំង៤ខាងលើនេះ ក្នុងចំណោមនោះ អង្គហេតុក្នុងករណីទី១ គឺជាចំណុចវិវាទ រីឯ អង្គហេតុក្នុងករណី២ មិនមែនជាចំណុចវិវាទនោះទេ ពីព្រោះថា ចំណុចដែលកើតមានក្នុងអង្គហេតុទី២ ពុំមានលក្ខណៈប្រកែកគ្នារវាងភាគីទាំង២នោះទេ តែបែរភាគីមានការយល់ស្រប និងទទួលស្គាល់ទៅនឹងអង្គហេតុទៅវិញ។ ដូចបានពន្យល់ក្នុងនិយមន័យនៃ ចំណុចវិវាទខាងលើ ចំណុចដែលមានការប្រកែកមិនយល់ព្រម មិនពេញចិត្តរបស់ភាគី គឺជាចំណុចវិវាទ។ ទោះបីជាយ៉ាងណាក៏ដោយ ករណីទី១ និង ទី២ ពុំមែនជាបញ្ហាចោទខ្លាំងនោះទេ។ ប៉ុន្តែបញ្ហាកើតមានឡើងនៅក្នុងករណីទី៣ និង ទី៤។ ជាការពិតនៅក្នុងករណីនៃការធ្វើសេចក្តីថ្លែងការណ៍អំពីការមិនបានដឹង ក្រមនីតិវិធីរដ្ឋប្បវេណីសន្មតអាកប្ប-

[40] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១០៣

[41] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១២៣ កថាខណ្ឌទី២

កិរិយានោះថាជា ការតវ៉ាចំពោះអង្គហេតុ[42] ហើយចំពោះករណីដែលភាគីមិនឆ្លើយអ្វីទាំងអស់វិញ ត្រូវចាត់ទុកថា ភាគីបានសារភាពអំពីអង្គហេតុ លើកលែងតែ ក្នុងករណីដែលតុលាការយល់ឃើញថា ភាគីនោះបានតវ៉ាចំពោះអង្គហេតុនោះ ដោយគិតពិចារណាអំពីអាកប្បកិរិយាទាំងស្រុងរបស់ភាគីនោះ[43]។ ហេតុដូច្នេះហើយ អង្គហេតុដែលភាគីឆ្លើយថាមិនបានដឹង នឹងក្លាយទៅជាចំណុចវិវាទ។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការឆ្លើយតបទេ ត្រូវចាត់ទុកថាជាការសារភាព ហើយអង្គហេតុនោះនឹងមិនមែនជាចំណុចវិវាទឡើយ។ យោងតាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលភាគីបានសារភាព (រួមទាំងអង្គហេតុដែលសន្មតថាបានសារភាព) មិនចាំបាច់ធ្វើការបញ្ជាក់ដោយភស្តុតាងឡើយ។[44]

ដូចនេះ តុលាការធ្វើការកំណត់នូវចំណុចវិវាទនៃរឿងក្តីនេះ តាមរយៈការបង្គាប់ឲ្យភាគីធ្វើការបំភ្លឺអំពីអង្គហេតុផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាមូលហេតុផ្ទាល់នៃការបង្កើតសិទ្ធិ ដែលដើមចោទបានអះអាង និង អំពីរឿងរ៉ាវលម្អិតនៃរឿងក្តី និង តាមរយៈការបង្គាប់ឲ្យភាគីធ្វើការបន្ថែម កែប្រែ ឬដកចេញនូវការអះអាងរបស់ខ្លួន។ ការធ្វើបែបនេះ គេហៅថា "ការរៀបចំការអះអាង" ឬ "ការរៀបចំចំណុចវិវាទ" ដែលនាំឲ្យ ចំណុចវិវាទពិតប្រាកដត្រូវបានកំណត់ និងត្រូវបានទទួលស្គាល់រួមគ្នាដោយតុលាការ និងភាគីទាំងសងខាង។

### ២.១.២.៣. ការរៀបចំភស្តុតាង

តុលាការត្រូវកំណត់នូវភស្តុតាងពាក់ព័ន្ធនានាទៅនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យបន្ទាប់ពីចំណុចវិវាទត្រូវបានកំណត់រួចរាល់។ ភស្តុតាងត្រូវមានសាក្សី ការសាកសួរសាមីភាគី ការធ្វើកោសលវិច័យ ឯកសារ និង ការត្រួតពិនិត្យភស្តុតាងដែលស្នើសុំឲ្យពិនិត្យ។

នៅក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ អាចពិនិត្យភស្តុតាងជាឯកសារ ដើម្បីបញ្ជាក់ថាឯកសារនោះត្រឹមត្រូវ។[45] ឯកសារឯកជនដែលមានចុះហត្ថលេខារបស់សាមីខ្លួន និង អ្នកតំណាងត្រូវចាត់ទុកថាជា ឯកសារត្រឹមត្រូវ។[46] ក្រោយពីពិនិត្យភស្តុតាងរួចមក តុលាការត្រូវសងសំណើដើម

[42] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៩៦ កថាខណ្ឌទី២
[43] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៩៦ កថាខណ្ឌទី១
[44] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១២៣ កថាខណ្ឌទី ២
[45] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥៥ កថាខណ្ឌទី១
[46] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥៥ កថាខណ្ឌទី៥

ឲ្យទៅភាគីវិញ ហើយបញ្ជូនឯកសារចម្លងចូលក្នុងសំណុំរឿង។ ក្នុងករណីចាំបាច់ តុលាការអាចឃាត់ទុកឯកសារនោះបាន។[47]

## ក. ប្រភេទនៃភស្តុតាង

មុននឹងធ្វើការបកស្រាយពីប្រភេទនៃភស្តុតាង យើងត្រូវយល់ថាអ្វីជាភស្តុតាងជាមុនសិន។ ភស្តុតាង គឺជាតឹកតាងជាលាយលក្ខណ៍អក្សរ ឬ មិនលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងចំណុចវិវាទរវាងគូភាគី ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។[48]

ភស្តុតាងត្រូវបានបែងចែកជា៤ប្រភេទធំៗ៖[49]

- **ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល**

ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលបញ្ជាក់ដោយផ្ទាល់ អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុផ្ទាល់ (អង្គហេតុចម្បង) ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌផ្ទាល់នៃអានុភាពគតិយុត្ត គឺការបង្កើត ការផ្លាស់ប្តូរ ឬ ការរំលត់សិទ្ធិ និង កាតព្វកិច្ច។

ភស្តុតាងដោយប្រយោល គឺជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុប្រយោល និង អង្គហេតុបន្ទាប់បន្សំ ដែលមានប្រយោជន៍ក្នុងការបញ្ជាក់អំពីអង្គហេតុផ្ទាល់។ ក្នុងករណីដែលពុំមានភស្តុតាងផ្ទាល់ទេ ចាំបាច់ត្រូវបញ្ជាក់អំពីអង្គហេតុប្រយោល ដោយផ្អែកលើភស្តុតាងប្រយោល ហើយត្រូវបញ្ជាក់អំពីអង្គហេតុផ្ទាល់ ដោយធ្វើការសន្និដ្ឋានអំពីអង្គហេតុផ្ទាល់ តាមរយៈការអនុវត្តវូបមន្តនៃបទពិសោធន៍ (វិធានតាមបទពិសោធន៍)។ អង្គហេតុបន្ទាប់បន្សំ គឺជាអង្គហេតុស្តីពីលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ដែលអាចយកទៅប្រើប្រាស់ជាភស្តុតាងបាន(អំណាច ឬសមត្ថភាពជាភស្តុតាង) ឬអង្គហេតុស្តីពីអានុភាពដែលជួយឲ្យចៅក្រមមានការជឿជាក់លើអ្វីមួយ (តម្លៃជាភស្តុតាង)។

<u>**ឧទាហរណ៍៖**</u> អង្គហេតុបន្ទាប់បន្សំ មានដូចជា អង្គហេតុស្តីពីភាពគួរឲ្យជឿជាក់នៃសេចក្តីថ្លែងការណ៍របស់សាក្សី ឬ អង្គហេតុស្តីពីបញ្ហាថា តើឯកសារណាមួយត្រូវបានបង្កើតឡើង ដោយត្រឹម

[47] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៤៨ កថាខណ្ឌទី៣

[48] សន្ទានុក្រមពាក្យច្បាប់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

[49] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ទំព័រទី៩៣

ត្រូវដែរ ឬទេ។[50]

- **ភស្តុតាងជាមនុស្ស និងភស្តុតាងជាវត្ថុ**

ភស្តុតាងជាមនុស្ស សំដៅទៅលើមនុស្ស ក្នុងករណីដែលសាកសួរមនុស្សនោះ ដើម្បីយកសេចក្ដីថ្លែងការណ៍របស់មនុស្សនោះ មកធ្វើជាភស្តុតាង។ ភស្តុតាងជាមនុស្សមានដូចជា សាក្សី អ្នកជំនាញការខាងកោសលវិច័យ ឬ សាមីភាគី (រួមទាំងអ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ។)[51]

ភស្តុតាងជាវត្ថុ សំដៅទៅលើឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលមានកម្មវត្ថុក្រៅពីមនុស្ស មានដូចជាឯកសារ និងវត្ថុដែលត្រូវធ្វើការត្រួតពិនិត្យ។ ទោះបីជាក្នុងករណីដែលកម្មវត្ថុនៃភស្តុតាង គឺជាមនុស្សក៏ដោយ ក្នុងករណីដែលសង្កេតពីអត្តចរិត តាមរយៈទឹកមុខរបស់បុគ្គលនោះ និង ការពិនិត្យស្នាមម្រាមដៃរបស់បុគ្គលនោះ ភស្តុតាងនោះគឺជាវត្ថុដែរ។

- **ភស្តុតាងស្រប និងភស្តុតាងផ្ទុយ**

ភស្តុតាងស្របគឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគី ដើម្បីបញ្ជាក់អំពីអង្គហេតុផ្ទាល់ដែលខ្លួនមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ផ្ទាល់ខ្លួន។

ភស្តុតាងផ្ទុយ គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគីម្ខាងទៀត ដែលធ្វើការតវ៉ាចំពោះអង្គហេតុដែលត្រូវបានអះអាង។ ចំណុចនេះមានន័យថា ធ្វើសេចក្ដីថ្លែងការណ៍ថាបដិសេធនូវអង្គហេតុ ឬ មិនបានដឹងអំពីអង្គហេតុនោះ។[52]

បន្ថែមពីនេះ គោលបំណងនៃភស្តុតាងស្រប គឺធ្វើឲ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់។ ផ្ទុយទៅវិញ ភស្តុតាងផ្ទុយ មានគោលបំណងរារាំងចៅក្រមមិនឲ្យមានជឿជាក់ដោយផ្អែកលើភស្តុតាងស្រប ឬផ្លាស់ប្ដូរការជឿជាក់ដែលចៅក្រមមានរួចហើយ។ ភស្តុតាងស្រប អាចសម្រេចគោលបំណងរបស់វា តែក្នុងករណីដែលបានធ្វើឲ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់ណាមួយ តែប៉ុណ្ណោះ។ ដោយឡែក ភស្តុតាងផ្ទុយ អាចសម្រេចគោលបំណងរបស់វា

[50] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥៥

[51] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៩២

[52] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៩៦ កថាខណ្ឌទី ២

ដោយគ្រាន់តែធ្វើឲ្យការជឿជាក់របស់ចៅក្រមទៅលើអត្ថិភាពនៃអង្គហេតុនៅពេលនោះ មានភាពមិនច្បាស់លាស់តែប៉ុណ្ណោះ ពោលគឺមិនចាំបាច់ធ្វើឲ្យចៅក្រមមានការជឿជាក់ទៅលើនត្ថិភាពនៃអង្គហេតុទេ។

- **ភស្តុតាងជាឯកសារ**

ភស្តុតាងជាឯកសារ គឺជាការពិនិត្យភស្តុតាងដោយការអានឯកសារ ហើយយកខ្លឹមសារដែលសរសេរនៅក្នុងនោះ មកធ្វើជាធនធានភស្តុតាង។

ប្រភេទនៃឯកសារក្នុងភស្តុតាងនេះមាន៣ប្រភេទទៀត ដូចជា៖

- ឯកសារសាធារណៈ និង ឯកសារឯកជន

ឯកសារដែលធ្វើឡើងដោយមន្ត្រីរាជការក្នុងការបំពេញមុខនាទីរបស់ខ្លួន ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន គឺជាឯកសារសាធារណៈ ហើយឯកសារក្រៅពីនេះ គឺជាឯកសារឯកជន។ **<u>ឧទាហរណ៍</u>**៖ មូលសាលក្រម កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃបញ្ជីអត្រានុកូលដ្ឋាន ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃសៀវភៅគោលបញ្ជីដីធ្លី។ ចំពោះឯកសារសាធារណៈ បើទទួលស្គាល់តាមទម្រង់ និង ខ្លឹមសារនៃឯកសារនោះ ថាឯកសារនោះត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខ តួនាទី ភាពត្រឹមត្រូវនៃការបង្កើតឯកសារនេះត្រូវបានសន្មត[53] ហេតុនេះហើយ អ្នកស្នើសុំឲ្យពិនិត្យឯកសារនោះ មិនចាំបាច់ធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះទេ។ ផ្ទុយទៅវិញ ចំពោះឯកសារឯកជន ចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ ក៏ប៉ុន្តែ ប្រសិនបើនៅក្នុងឯកសារឯកជននោះមានហត្ថលេខារបស់សាមីខ្លួន ឬរបស់អ្នកតំណាង (អ្នកដែលបានធ្វើឯកសារ) ភាពត្រឹមត្រូវក្នុងការបង្កើតឯកសារនោះត្រូវបានសន្មត។ ដូច្នេះហើយ ភាគីម្ខាងទៀតដែលធ្វើវិវាទអំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារឯកជនបែបនេះ ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើង ដោយខុសពីឆន្ទៈរបស់អ្នកដែលបានធ្វើឯកសារ។

[53] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥៥ កថាខណ្ឌទី២

- ឯកសារចាត់ចែង និង ឯកសាររបាយការណ៍

ក្នុងករណីដែលសកម្មភាពគតិយុត្ត ជាដើម ធ្វើឡើងដោយឯកសារ ដូចជា មតកសាសន៍ រូបិយាណត្តិ លិខិតកិច្ចសន្យា ជាដើម ឯកសារនោះត្រូវហៅថា ឯកសារចាត់ចែង។ ឯកសារក្រៅពីនេះ ដូចជាវិក័យប័ត្រសំបុត្រពេទ្យ សំបុត្រកំណត់ប្រចាំថ្ងៃ កំណត់ហេតុ ជាដើម ដែលមានសរសេរអំពីការយល់ដឹងស្តីពីអង្គហេតុ ការវិនិច្ឆ័យ មនោគមវិជ្ជា ចំណាប់អារម្មណ៍ ជាដើម របស់អ្នកធ្វើឯកសារ គេហៅឯកសាររបាយការណ៍។ ចំពោះឯកសារចាត់ចែង ប្រសិនបើបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះហើយ សកម្មភាពគតិយុត្ត ដែលជាខ្លឹមសារនៅក្នុងឯកសារនោះ ក៏ត្រូវបានបញ្ជាក់ថា ត្រូវបានធ្វើឡើងដែរ។ ចំពោះឯកសាររបាយការណ៍វិញ ទោះជាបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះក៏ដោយ ក៏សមត្ថភាព/អំណាច ជាសារធាតុនៃភស្តុតាង មានការខុសគ្នាទៅតាមខ្លឹមសារនៃការសរសេរក្នុងឯកសារនោះ។

- ច្បាប់ដើម (ឯកសារដើម) ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តី-បញ្ជាក់

ច្បាប់ដើម (ឯកសារដើម) គឺមានន័យថា ជាសំណៅដើម ឬ ឯកសារពិត។ រីឯឯកសារចម្លងដែលមានសេចក្តីបញ្ជាក់វិញ គឺជាឯកសារដែលបានចម្លងតាមខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) ទាំងស្រុងតែម្តង ហើយដែលជាឯកសារចម្លងយថាភូតវិញ គឺជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ដែលបានធ្វើឡើងដើម្បីឲ្យមានអានុភាពតាមផ្លូវច្បាប់ ដូចច្បាប់ដើម (ឯកសារដើម) ដែរ។

**<u>ឧទាហរណ៍៖</u>** ក្នុងការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្ត នៃលិខិតអនុវត្តផងដែរ។[54]

### ខ.ការពិនិត្យភស្តុតាងជាឯកសារ

នៅក្នុងនីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ ការពិនិត្យភស្តុតាងអាចធ្វើឡើងតាមការស្នើសុំឲ្យពិនិត្យរបស់គូភាគី។[55] ការណ៍នេះអាចធ្វើឡើងដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរក៏បានដែរ។

[54] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣៤៩ កថាខណ្ឌទី២

[55] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១២៤ កថាខណ្ឌទី១

ការស្នើសុំឲ្យពិនិត្យភស្តុតាងនេះ អាចធ្វើនៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬមុនកាលបរិច្ឆេទនៃនីតិវិធីទាញហេតុហេតុផលដោយផ្ទាល់មាត់បាន។[56] តុលាការអាចចេញសេចក្តីសម្រេចទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាងនេះ។ ពាក្យ "ដីកាសម្រេច" នេះ ពុំតម្រូវចាំបាច់ឲ្យសរសេរជាលាយលក្ខណ៍អក្សរទេ[57] គឺអាចធ្វើដោយផ្ទាល់មាត់បានព្រោះគូភាគីមានវត្តមានទាំងអស់គ្នា តែត្រូវចុះក្នុងកំណត់ហេតុ។

ចំពោះភស្តុតាងដែលអាចទទួលយកមកពិនិត្យក្នុងនីតិវិធីនេះបាន គឺមានតែភស្តុតាងជាឯកសារក្នុងកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និង ភស្តុតាងប៉ុណ្ណោះ[58] ចំពោះភស្តុតាងជាសាក្សីភាគីអាចស្នើសុំដាក់នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបាន ប៉ុន្តែច្បាប់មិនអនុញ្ញាតឲ្យមានការសាកសួរសាក្សីក្នុងដំណាក់កាលនេះឡើយ។

ម្យ៉ាងទៀត ចំពោះអង្គហេតុដែលត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវឲ្យភាគីស្នើសុំពិនិត្យភស្តុតាងនោះនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឲ្យហើយដែរ ដោយហេតុថានៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីពុំអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីទៀតទេ លើកលែងមានករណីពិសេស។[59]

### គ. ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឲ្យពិនិត្យ ប៉ុន្តែវាមិនអាចអនុវត្តបានឡើយចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ។[60]

---

[56] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១២៥ កថាខណ្ឌទី៣

[57] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១៣

[58] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១០៦

[59] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១០៨

[60] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១២៦

### ២.១.២.៤. ការបំបែក ឬ ការបញ្ចូលរឿងក្តី

នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការអាចបំបែកបណ្តឹងទាមទារ មួយភាគដោយដីកាសម្រេច ហើយធ្វើការវិនិច្ឆ័យដាច់ដោយឡែកពីគ្នាបាន ឬលុបចោលដីកាសម្រេច។ ម្យ៉ាងវិញទៀតតុលាការក៏អាចបញ្ចូលរឿងក្តីទាំងអស់នោះ មានភាគីខុសគ្នាក៏ដោយ។

### ២.១.៣. ដីកាសម្រេចដែលមិនមែនជាសាលក្រម

ដីកាសម្រេច គឺជាការសម្រេចសេចក្តីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បានហើយមិនមែនជាសាលក្រម។[61] និយាយម្យ៉ាងទៀត ដីកាសម្រេច គឺជាសម្រេចសេចក្តីដើម្បីចាត់ការលើការដឹកនាំនីតិវិធី ឬ ដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្តឹង ហើយមិនមែនជាការសម្រេចសេចក្តីសំខាន់ៗដូចសាលក្រមដែលវិនិច្ឆ័យអង្គសេចក្តីទេ។

ដើម្បីយល់ឲ្យបានកាន់តែច្បាស់អំពីវិធានទាក់ទងនឹងដីកាសម្រេច យើងត្រូវសិក្សាពីរបៀបចេញដីកាសម្រេច ពីអានុភាព និង ការប្តឹងតវ៉ាចំពោះដីកាសម្រេច ដែលឆ្លុះបញ្ចាំង និងបង្ហាញឲ្យឃើញពីភាពខុសប្លែកគ្នាជាមួយនឹងសាលក្រម។

#### ២.១.៣.១. របៀបចេញដីកាសម្រេច

ដូចបានពន្យល់នូវនិយមន័យនៃដីកាសម្រេចខាងលើ ដីកាសម្រេចជាសេចក្តីសម្រេចរបស់ចៅក្រម ឬតុលាការ។ "ចៅក្រម" ជាពាក្យមានន័យទូលាយ សំដៅទៅលើមនុស្សម្នាក់ដែលត្រូវតែងតាំងឲ្យបំពេញមុខងារជាចៅក្រម។ "តុលាការ" ជាពាក្យដែលគេប្រើនៅក្នុងន័យច្រើនយ៉ាង។ តុលាការអាចសំដៅទៅលើស្ថាប័ននៃអំណាចតុលាការដែលជាស្ថាប័នមានសមត្ថកិច្ចជំនុំជម្រះក្តី។ តុលាការអាចសំដៅទៅលើក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមម្នាក់ដែលទទួលបន្ទុកដោះស្រាយរឿងក្តីណាមួយ ហើយប្រើប្រាស់អំណាចតុលាការដោយឯករាជ្យ។ បន្ថែមពីនេះ ពាក្យចៅក្រម និង តុលាការត្រូវបានប្រើប្រាស់ទាំងពីរក្នុងមាត្រា១៧៩ កថាខណ្ឌទី២ ក្នុងន័យថា ពេលខ្លះគេចេញដីកាសម្រេច គ្រាន់តែមាន

[61] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៧៩ កថាខណ្ឌទី២

គោលបំណងរៀបចំកិច្ចការរដ្ឋបាល និង ដំណើរការរបស់ស្ថាប័នតុលាការឲ្យប្រព្រឹត្តទៅបានល្អ មិនមែនក្នុងគោលបំណងដោះស្រាយរឿងក្តីណាមួយនោះទេ។

**ឧទាហរណ៍៖** ដីកាសម្រេចបែងចែករឿងក្តី ឬ កែប្រែលំដាប់បែងចែករឿងក្តី។ ដីកានេះត្រូវចេញដោយប្រធានតុលាការ។[62]

ចំណែកឯមាត្រា១៧៩ កថាខណ្ឌទី១ ដែលបានឲ្យនិយមន័យទៅលើសាលក្រមវិញ តែជាសេចក្តីសម្រេចរបស់តុលាការដោយពុំប្រើពាក្យ "សាលក្រម" ទេ។ នេះគឺមានន័យថា សាលក្រម គឺជាសេចក្តីសម្រេចដែលទាក់ទងនឹងការដោះស្រាយវិវាទរឿងក្តីតែម្តង។ អាស្រ័យទៅតាមករណីនីមួយៗ ដីកាសម្រេចអាចចេញដោយចៅក្រមតែម្នាក់ ឬ ដោយក្រុមប្រឹក្សាជនុំជម្រះ។

ដីកាសម្រេច គឺជាសេចក្តីសម្រេចដែលអាចធ្វើដោយផ្ទាល់មាត់ក៏បាន ធ្វើជាលាយលក្ខណ៍អក្សរក៏បាន។ ការអះអាងបែបនេះ គឺផ្អែកទៅលើការបកស្រាយក្នុងក្រមនីតិវិធីរដ្ឋប្បវេណី[63] ដែលចែងថា ក្នុងករណីចេញ "ដីកាសម្រេចជាលាយលក្ខណ៍អក្សរ"។ ការប្រើពាក្យបែបនេះ អាចឲ្យយើងសន្និដ្ឋានបានថា ដីកាសម្រេចខ្លះក៏អាចធ្វើដោយផ្ទាល់មាត់បានដែរ។ ប្រសិនបើ ដីកាសម្រេចធ្វើដោយផ្ទាល់មាត់ ដីកាសម្រេចនេះត្រូវកត់ត្រានៅក្នុងកំណត់ហេតុ ដើម្បីទុកជាបន្ទាល់បញ្ជាក់ទៅថ្ងៃក្រោយ។

ជាក់ស្តែង ច្បាប់ (ការសម្រេចសេចក្តីដែលបានធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ)[64] ត្រូវឲ្យកត់ត្រា នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នូវសេចក្តីសម្រេច ដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចនេះគឺ មិនមានអ្វីក្រៅពីដីកាសម្រេច (វាមិនមែនជាសាលក្រម)នោះទេ ព្រោះថាសេចក្តីសម្រេចដែលមិនមែនជាសាលក្រម គឺជាដីកាសម្រេច។

ការធ្វើដីកាសម្រេចជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់គឺវាអាស្រ័យទៅតាមករណីនីមួយៗ តាមការយល់ឃើញរបស់ចៅក្រម ឬ តុលាការដែលចេញដីកាសម្រេច ប៉ុន្តែក្នុងករណីខ្លះវិញ

[62] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៦ កថាខណ្ឌទី១

[63] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១៣ កថាខណ្ឌទី២

[64] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១១១ ចំណុច ចនិង មាត្រា ១១៩ ចំណុច ច

ច្បាប់តម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរតែម្តង ដូចជាករណីនៃដីកាសម្រេចដាស់តឿនជាអាទិ៍[65]។ ក្នុងករណីខ្លះ ច្បាប់ពុំបានតម្រូវថាយ៉ាងដូចម្តេចទេ ហេតុនេះចៅក្រម ឬ តុលាការអាចចេញដីកាសម្រេចជាលាយលក្ខណ៍អក្សរក៏បាន ដោយផ្ទាល់មាត់ក៏បាន។ ប៉ុន្តែក្នុងករណីមួយចំនួនដោយផ្អែកទៅលើស្ថានភាពនៃការអនុវត្តជាក់ស្តែង យើងប្រហែលជាមិនឃើញដីកាសម្រេចធ្វើដោយផ្ទាល់មាត់បានទេ ដូចជាករណីនៃដីកាសម្រេចចេញដោយប្រធានតុលាការ ដើម្បីកំណត់ការបែងចែករឿងក្តីជារៀងរាល់មួយឆ្នាំម្តង។ ត្រង់ចំណុចនេះក៏បង្ហាញឲ្យឃើញភាពខុសប្លែកគ្នាជាមួយនឹងសាលក្រម ដែលដាច់ខាតត្រូវចេញជាលាយលក្ខណ៍អក្សរ[66] ចំណែកឯ ដីកាសម្រេចវិញ គឺជាសេចក្តីសម្រេចរបស់តុលាការ ឬចៅក្រមដែលមានគោលបំណងដើម្បីចាត់ការលើការដឹកនាំនីតិវិធីនៃបណ្តឹង។

**<u>ឧទាហរណ៍៖</u>** ដីកាសម្រេចទាក់ទងនឹងបណ្តឹងជិតជិត ដីកាសម្រេចឲ្យជំនុំជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ ជាដើម។ ឬ ក្នុងគោលបំណងដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្តឹងប៉ុណ្ណោះ។ **<u>ឧទាហរណ៍៖</u>** ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួន ដីកាសម្រេចទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាងជាដើម។

ជាគោលការណ៍ ការចេញដីកាសម្រេចមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ព្រោះថាដីកាសម្រេច សម្រេចតែអំពីចំណុចបន្ទាប់បន្សំនៃនីតិវិធីប៉ុណ្ណោះ។ ច្បាប់[67]បានទុកលទ្ធភាពឲ្យចៅក្រមសម្រេចថាតើត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ អត់ ដោយយោងតាមករណីនីមួយៗ ហើយទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការអាចសួរភាគីបាន ពោលគឺ តុលាការផ្តល់ឱកាសឲ្យភាគីធ្វើសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់ ឬ ជាលាយ-លក្ខណ៍អក្សរទាក់ទិននឹងចំណុចដែលត្រូវសម្រេចដោយដីកាសម្រេច។ ផ្ទុយទៅវិញ ជាគោលការណ៍ សាលក្រមត្រូវសម្រេចដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីពិសេសដែលមានបញ្ញត្តិក្នុងច្បាប់[68]។

[65] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣២៤
[66] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៨៩
[67] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១១៤
[68] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៨១

### ២.១.៣.២. អានុភាពនៃដីកាសម្រេច

ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែបានជូនដំណឹងតាមវិធីដែលទទួលស្គាល់ថាសមរម្យ។[69] ហេតុនេះ ចំពោះដីកាសម្រេចធ្វើដោយផ្ទាល់មាត់ចំពោះមុខភាគីដីកាសម្រេចនឹងបង្កើតអានុភាពអនុវត្តភ្លាម នៅពេលដែលតុលាការ ឬ ចៅក្រមបានសម្រេចសេចក្តីដោយដីកាសម្រេចនោះ។ ចំពោះដីកាសម្រេចដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរចៅក្រមត្រូវចុះ ហត្ថលេខា ហើយជូនដំណឹងពីដីកាសម្រេចនោះទៅដល់អ្នកពាក់ព័ន្ធហើយ មានអានុភាពភ្លាមៗតែម្តង លើកលែងតែករណីផ្សេងកំណត់ដោយច្បាប់។

**<u>ឧទាហរណ៍៖</u>** ចំពោះដីកាសម្រេចដាស់តឿន[70] កំណត់ថាដីកាសម្រេចដាស់តឿនត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល។

ក្រៅពីនីតិវិធីបញ្ជូន វិធីជូនដំណឹងដីកាសម្រេចអាចធ្វើបានតាមគ្រប់រូបភាពផ្សេងទៀត ដែលទទួលស្គាល់ថាសមរម្យ។ ក្នុងន័យនេះ ការជូនដំណឹងអំពីដីកាសម្រេច អាចធ្វើដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ អាចធ្វើតាមរយៈទូរស័ព្ទ ឬ ទូរសារ ជាដើម។ ដើម្បីជាតឹកតាងនៃជូនដំណឹង ក្នុងច្បាប់[71] តម្រូវឲ្យក្រឡាបញ្ជីបញ្ជាក់ឲ្យបានច្បាស់លាស់នូវហេតុ-ការណ៍ និង វិធីនៃការជូនដំណឹងដាក់នៅក្នុងសំណុំរឿង។ ផ្ទុយពីដីកាសម្រេច សាលក្រមនឹងមានអានុភាពដោយការប្រកាស[72] ហើយតុលាការអាចប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នបាន។ ដោយមូលហេតុថា ដីកាសម្រេចមានអានុភាព អនុវត្តភ្លាមៗក្រោយការជូនដំណឹង ដូច្នេះការប្រកាសឲ្យមានការអនុវត្តជាបណ្តោះអាសន្នដែលអនុវត្តសម្រាប់សាលក្រម ក៏ពុំមានអានុភាពសម្រាប់ដីកាសម្រេចដែរ។

ដីកាសម្រេចដែលមានគោលដៅត្រឹមតែដឹកនាំនីតិវិធីនៃបណ្តឹង អាចលុបចោលនាពេលណាក៏បាន[73] ដោយហេតុថា ដីកាសម្រេចមានពីរប្រភេទគឺ ដីកាដែលមានគោលបំណង ចាត់ការលើការដឹកនាំ

---

[69] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១៣ កថាខណ្ឌទី១

[70] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣២៥

[71] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១៣ កថាខណ្ឌទី៣

[72] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៨៦

[73] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១៤

នីតិវិធីនៃបណ្តឹង និង ដីកាដែលមានគោលបំណងដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្តឹង។ ហេតុនេះតាមការបកស្រាយដែលមានលក្ខណៈផ្ទុយមកវិញមានន័យថា មានតែដីកាសម្រេចដែលមានគោលដៅដឹកនាំនីតិវិធីនៃបណ្តឹងប៉ុណ្ណោះ ដែលអាចលុបចោលបានពេលណាក៏បាន ចំណែកឯដីកាសម្រេចផ្សេងទៀតក្រៅពីដីកានេះ មិនស្ថិតក្រោមបទបញ្ញត្តិនៃមាត្រា ២១៩ទេ។ **ឧទាហរណ៍៖** ប្រសិនបើ តុលាការយល់ឃើញថា ការបង្គាប់ឲ្យដាក់ឯកសារត្រៀម ក្នុងអំឡុងពេលណាមួយមានលក្ខណៈមិនសមរម្យដោយហេតុពេលវេលាខ្លីពេកជាដើម ឬ មួយក៏ចំណុចដែលត្រូវសរសេរចំណុចវិវាទទៀតហើយ តុលាការអាចលុបចោលដីកាសម្រេចនេះវិញបាន។ រីឯសាលក្រមវិញគឺ សុទ្ធតែមានអត្ថពន្ធភាព[74]។

មួយវិញទៀត ក្នុងច្បាប់[75]បានកំណត់ករណីបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមដែលត្រង់ចំណុចនេះមិនអាចយកមកអនុវត្តបានសម្រាប់រាល់ដីកាសម្រេចទាំងអស់នោះទេ។

**ឧទាហរណ៍៖** ដីកាសម្រេចអំពីពាក្យសុំពិនិត្យភស្តុតាង មានអានុភាពសម្រាប់តែភាគីពាក់ព័ន្ធប៉ុណ្ណោះ។

### ២.១.៣.៣. ការប្តឹងជំទាស់ពីដីកាសម្រេច

ដីកាសម្រេចទាំងអស់មិនសុទ្ធតែអាចប្តឹងជំទាស់បានទេ គឺលុះត្រាតែមានច្បាប់ចែង អនុញ្ញាតឲ្យប្តឹងជំទាស់បាន ទើបអាចប្តឹងជំទាស់បាន។[76] ក្រមនីតិវិធីរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យប្តឹងជំទាស់រាល់ដីកាសម្រេចទាំងអស់បាននោះទេ ព្រោះថាក្នុងករណីខ្លះ ការអនុញ្ញាតឲ្យប្តឹងជំទាស់ អាចធ្វើឲ្យអូសបន្លាយនីតិវិធីឥតប្រយោជន៍។ ហេតុនេះ ដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតជិតចិត្តមានមូលហេតុត្រឹមត្រូវនោះ មិនអាចប្តឹងឧបាស្រ័យឡើយ។[77] ដូចគ្នាដែរចំពោះ ដីកាសម្រេចបែងចែករឿងក្តី ឬ កែប្រែលំដាប់បែងចែករឿងក្តីក្រមនីតិវិធីរដ្ឋប្បវេណីពុំបានចែងហាមឃាត់ ឬ អនុញ្ញាតការប្តឹងជំទាស់ទេ។ ការណ៍នេះមានន័យថាគេពុំអាចប្តឹងជំទាស់បានឡើយ។[78]

[74] អត្ថពន្ធភាពនៃសាលក្រម មានន័យថា សាលក្រមមានអានុភាពចងតុលាការដែលបានប្រកាសសាលក្រម ដោយតុលាការមិនអាចលុបចោល ឬ កែប្រែសាលក្រមនេះបានឡើយ លើកលែងតែករណីនៃដីកាសម្រេចកែតម្រូវ។
[75] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៩៨
[76] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៥៩ កថាខណ្ឌទី២
[77] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣០ កថាខណ្ឌទី៥
[78] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៦

ការប្តឹងជំទាស់ត្រូវដាក់ពាក្យទៅតុលាការដើមនៅក្នុងអំឡុងពេល១សប្តាហ៍ គិតចាប់តាំងពីថ្ងៃទទួលដំណឹងពីដីកាសម្រេច[79] ដែលចេញដីកាសម្រេច។[80] តុលាការដើមត្រូវផ្ញើឲ្យបានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់ និង សំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។ ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់ អំពីមូលហេតុនៃការទាមទារឲ្យតុលាការលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើមក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរអំពីចំណុចនោះទៅតុលាការនៃបណ្តឹងជំទាស់នៅក្នុងអំឡុងពេល២សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។ អំឡុងពេលមួយសប្តាហ៍នេះមិនអាចពន្យាបានឡើយ។ បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម។[81] តុលាការដែលសម្រេចលើបណ្តឹងជំទាស់ចេញដីកាសម្រេចមិនអាចប្តឹងជំទាស់ទៀតបានទេ។[82] មានន័យថា ដីកាសម្រេចពុំអាចត្រូវបានប្តឹងជំទាស់លើកទី២ឡើយ។

ពាក្យ "បណ្តឹងជំទាស់" មិនត្រូវភាន់ច្រឡំជាមួយនឹងពាក្យ "បណ្តឹងទាស់" ទេ។ បណ្តឹងទាស់ធ្វើឡើងដើម្បីជំទាស់ទៅនឹងសាលក្រមកំបាំងមុខ។[83]

### ២.១.៣.៤. ករណីចេញដីកាសម្រេច

ចំណុចខាងក្រោមនេះ គឺជាការដកស្រង់ខ្លះៗពីករណីចេញដីកាសម្រេច តាមក្រមនីតិវិធីរដ្ឋប្បវេណី៖

- ដីកាសម្រេចរបស់តុលាការកំពូល ក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច[84]
- ដីកាសម្រេចផ្ទេរសមត្ថកិច្ច ឬ លើកចោលពាក្យសុំផ្ទេរសមត្ថកិច្ច[85]
- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ[86]

[79] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣០៣ កថាខណ្ឌទី១
[80] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣០១ កថាខណ្ឌទី១
[81] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣០៥ កថាខណ្ឌទី១
[82] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៥៩ កថាខណ្ឌទី៣
[83] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២០៤
[84] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១២
[85] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២១
[86] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៣ កថាខណ្ឌទី៤

- ដីកាសម្រេចបែងចែករឿងក្តី ឬ កែប្រែលំដាប់បែងចែករឿងក្តី[87]
- ដីកាសម្រេចទាក់ទងនឹងការដកហូត និង បណ្តឹងជិតជិត[88]
- ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យចូលរួមជួយអន្តរាគមន៍[89]
- ដីកាសម្រេចទាក់ទងនឹងប្រាក់ប្រដាប់ក្តី[90]
- ដីកាសម្រេចទាក់ទងនឹងប្រាតិភោគលើប្រាក់ប្រដាប់ក្តី[91]
- ដីកាសម្រេចឲ្យជួយសង្គ្រោះលើបណ្តឹង[92]
- ដីកាសម្រេចលើកពាក្យបណ្តឹងចោល[93]
- ដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង[94]
- ដីកាសម្រេចចំពោះបណ្តឹងតវ៉ាចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុដោយផ្ទាល់មាត់ ឬ ចំពោះការចាត់ចែងរបស់តុលាការ[95]
- ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួន[96]
- ដីកាសម្រេចបំបែក ឬ បញ្ចូលសំណុំរឿង[97]
- ដីកាសម្រេចទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាង[98]
- ដីកាសម្រេចបង្គាប់ឲ្យដាក់ឯកសារត្រៀមក្នុងអំឡុងពេលណាមួយ[99]
- ដីកាសម្រេចឲ្យធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលជាថ្មីម្តងទៀត[100]
- ដីកាសម្រេចទៅលើការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី[101]

[87] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ២៦ កថាខណ្ឌទី១-៣
[88] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣០
[89] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៤៥
[90] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៦២ មាត្រា ៦៤ និង មាត្រា ៦៥
[91] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៦៧ មាត្រា ៧១ និង មាត្រា ៧៣
[92] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៦៩
[93] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៧៨ កថាខណ្ឌទី២ និង មាត្រា ៨២
[94] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៨៤ កថាខណ្ឌទី៤
[95] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៩១
[96] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៩៤
[97] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៩៩
[98] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១០៦
[99] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១០២
[100] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១១៦ កថាខណ្ឌទី៤

- ដីកាសម្រេចពិន័យភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍[102]
- ដីកាសម្រេចទាក់ទងនឹងបណ្តឹងផាត់ចោលអ្នកជំនាញ[103]
- ដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ[104]
- ដីកាសម្រេចពិន័យផ្សេងៗ[105]
- ដីកាសម្រេចឲ្យថែរក្សាការពារភស្តុតាង[106]
- ដីកាសម្រេចលើកចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង
- ដីកាសម្រេចឲ្យបន្តនីតិវិធីនៃបណ្តឹង[107]
- ដីកាសម្រេចបង្គាប់ឲ្យបង្អង់នីតិវិធីនៃបណ្តឹង[108]
- ដីកាសម្រេចដើម្បីចាប់ផ្តើមធ្វើការជំនុំជម្រះសារជាថ្មី[109]
- ដីកាសម្រេចដាស់តឿន[110]
- ដីកាសម្រេចផ្សេងៗទាក់ទងនឹងការអនុវត្តដោយបង្ខំ[111]។

## ២.១.៤. ការស្នើសុំផ្ទេរសមត្ថកិច្ចដោយឆន្ទានុសិទ្ធរបស់តុលាការ

### ២.១.៤.១.ការផ្ទេរសមត្ថកិច្ចតុលាការ

នៅក្នុងករណីដែលមានចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី ដោយតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬផ្នែកណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច។ ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើក

[101] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៣៥
[102] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៤០
[103] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៤៥
[104] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥២
[105] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៥៤ មាត្រា ១៥៦ និង មាត្រា ១៥៧
[106] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៦៧
[107] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៧៥ និង មាត្រា ១៧៦
[108] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ១៧៧
[109] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣១៥
[110] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣១៩
[111] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា ៣៩៥

លែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ។ មួយវិញទៀត នៅពេលធ្វើពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ។

តុលាការក៏អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីធ្វើការផ្ទេរបណ្តឹងដើម្បីជៀសវាងពីការយឺតយ៉ាវ។ ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬដើម្បីឲ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សីដែលត្រូវសាកសួរ ទីតាំងវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និងកាលៈទេសៈផ្សេងៗទៀត ដែលក្នុងនោះតុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬផ្នែកណាមួយទៅឲ្យតុលាការផ្សេងទៀតដែលមានសមត្ថកិច្ច។ ប៉ុន្តែ តុលាការអាចសួរយោបល់របស់គូភាគីបាន ដើម្បីធ្វើការសម្រេចផ្ទេរសមត្ថកិច្ច។ យ៉ាងណាមិញ ទោះបីជាតុលាការអាចផ្ទេរសមត្ថកិច្ចដើម្បីជៀសវាងការយឺតយ៉ាវក៏ដោយ វាក៏មិនអាចយកមកអនុវត្តបានឡើយ ចំពោះករណីដែលបណ្តឹងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការបណ្តឹងនោះ។

### ២.១.៤.២.ការដកហូតសមត្ថកិច្ចជំនុំជម្រះ

ការដកហូតសមត្ថកិច្ចជំនុំជម្រះ គឺជារបៀបមួយដែលដកចៅក្រមពីការបំពេញមុខងារដោយស្វ័យប្រវត្តិតាមផ្លូវច្បាប់ ក្នុងករណីដែលមានហេតុដែលប៉ះពាល់ដល់សមភាពដោយធ្ងន់ធ្ងរ។ ករណីដែលអាចធ្វើការដកហូតសមត្ថកិច្ចបានមានដូចជា៖[112]

- ចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី
- ចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី៦ ឬញាតិពន្ធក្នុងថ្នាក់ទី៣ ឬអតីតញាតិពន្ធក្នុងថ្នាក់ទី៣របស់ភាគីណាមួយ។
- ចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- ចៅក្រមបានធ្វើជាសាក្សី ឬធ្វើជាអ្នកជំនាញក្នុងរឿងក្តី
- ចៅក្រមជាអ្នកតំណាង ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី។

[112] មាត្រា ២១ កថាខណ្ឌទី១ ចំណុច ក ដល់ ចំណុច ឆ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ២.២. សកម្មភាពរបស់ភាគី

### ២.២.១. ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលរបស់ភាគី

ក្រៅពីតួនាទី ក៏ដូចជាសមត្ថកិច្ចរបស់តុលាការ ដែលមានចៅក្រមជាតំណាងក្នុងរឿងក្ដីរដ្ឋប្បវេណីនេះ នៅក្នុងនីតិវិធីត្រៀមនេះទៀតសោត ភាគីទាំងសងខាងមានតួនាទីយ៉ាងសំខាន់ផងដែរ ដើម្បីឲ្យដំណើរការនៃនីតិវិធីទាំងមូលមានភាពរលូន និងស្របទៅតាមគោលការណ៍នៃច្បាប់។ ភាគីទាំងពីរ ដើមចោទ និងចុងចម្លើយត្រូវបំពេញនូវភារកិច្ចរបស់ខ្លួនដូចជា ២.២.១.១. ការដាក់សំណូមពរ និងការឆ្លើយតប ២.២.១.២. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន ២.២.១.៣.ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួន ២.២.១.៤. ការស្នើសុំឲ្យពិនិត្យភស្តុតាង២.២.១.៥.ការស្នើសុំឲ្យផ្លាស់ប្តូរសមត្ថកិច្ចតុលាការ បណ្ដឹងជំទាស់ និងការដកហូតសមត្ថកិច្ចតុលាការ និង ២.២.១.៦.ការដាក់ពាក្យបណ្ដឹងរបស់ភាគី ដូចខាងក្រោម។

#### ២.២.១.១. ការដាក់សំណូមពរ និងការឆ្លើយតប

ជាគោលការណ៍ តុលាការតែម្ខាងពុំអាចដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បាននោះទេ ដូច្នេះ ភាគីនៃបណ្ដឹងទាំងសងខាងមានកាតព្វកិច្ចចាំបាច់ក្នុងការចូលរួមអោយនីតិវិធីមួយនេះកើតឡើង តាមរយៈការដាក់ពាក្យបណ្ដឹងរបស់ដើមចោទ។ ដោយសង្កេតឃើញថា ទាំងចុងចម្លើយ និងដើមចោទសុទ្ធតែមានតួនាទីសំខាន់ៗ និងមានកាតព្វកិច្ច ក៏ដូចជាភារកិច្ចជាច្រើននៅក្នុងនីតិវិធីទាំងមូល។ រាល់តួនាទីរបស់អ្នកទាំងពីរនឹងធ្វើការបកស្រាយដូចខាងក្រោម។

##### ក. ការដាក់សំណូមពរ

ជាទូទៅអ្វីដែលជាសំណូមពរ (ការទាមទារ) របស់ដើមចោទត្រូវបានបង្ហាញឲ្យឃើញនូវក្នុងលិខិតនៃពាក្យបណ្ដឹង ដែលបានសរសេរនូវចំណុចខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ។ ភាគីបានសរសេរនូវអង្គហេតុចាំបាច់ដែលខ្លួនទាមទារអោយតុលាការធ្វើការសម្រេចសេចក្ដីនៅក្នុងពាក្យបណ្ដឹង ដែលស្ថិតក្នុងដំណាក់កាលនៃការដាក់ពាក្យបណ្ដឹង។

ផ្ដើមពីចំណុចនេះ តុលាការអាចកំណត់បានអំពីសកម្មភាពដែលត្រូវធ្វើនៅក្នុងកាលបរិច្ឆេទដូចជា ការផ្សះផ្សា ឬ ការថ្លែងការណ៍របស់ដើមចោទចំពោះការទាមទាររបស់ខ្លួន។ ដោយអាចដឹងបានអំពី

បញ្ហានៅក្នុងលិខិតនៃពាក្យបណ្តឹងនោះ តុលាការពុំចាំបាច់ឲ្យដើមចោទថ្លែងការណ៍អំពីពាក្យបណ្តឹងម្តងទៀតទេ។

### ខ.ការឆ្លើយតប

ក្រោយពីដើមចោទបានដាក់សំណូមពរដូចបានធ្វើការបង្ហាញ និងបញ្ជាក់ខាងលើរួចមក ចុងចម្លើយចាប់ផ្តើមធ្វើការឆ្លើយតបទៅនឹងសំណូមពរនោះ ដែលមានការបកស្រាយ នៅចំណុច ក និង ដូចខាងក្រោមនេះ។

- **សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ**

សេចក្តីថ្លែងការណ៍អំពីបណ្តឹងក៏ដូចជាសេចក្តីថ្លែងការណ៍អំពីឯកសារត្រៀមដែរ[113] គឺបានសេចក្តីថា ក្រមរដ្ឋប្បវេណីជ្រើសរើសយកគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់[114] ដូច្នេះហើយគ្រាន់តែដាក់ពាក្យបណ្តឹងមិនអាចក្លាយជាឯកសារបានទេ ចាំបាច់ត្រូវធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ តាមធម្មតាត្រូវធ្វើសេចក្តីថ្លែងការណ៍ជាសារធាតុ អំពីខ្លឹមសារនៃឯកសារនានាដោយផ្ទាល់មាត់។

- **ការឆ្លើយតបរបស់ចុងចម្លើយចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ឯកសារត្រៀមដែលចុងចម្លើយបានដាក់លើកដំបូង គឺជាឯកសារចម្លើយ។[115] ឯកសារត្រៀម ជាឯកសារដែលមានសរសេរអំពីខ្លឹមសារ ដែលភាគីចុងចម្លើយនឹងថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់ដើម្បីជូនដំណឹងជាមុនទៅភាគីម្ខាងទៀត និងតុលាការ។[116] ឯកសារនេះអាចអោយតុលាការ និងភាគីម្ខាងបានធ្វើការពិចារណាទៅលើខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ ហើយនិងបានត្រៀមចូលរួមក្នុងកាលបរិច្ឆេទបន្ទាប់ដើម្បីតតាំងអោយមានភាពល្អប្រសើរ។ ឯកសារនេះគប្បីដាក់អោយបានមុនកាលបរិច្ឆេទ ហើយតុលាការអាចធ្វើការកំណត់នូវអំឡុងពេលលើកដំបូងសម្រាប់ដាក់ឯកសារត្រៀមនេះ ឬឯកសារត្រៀម ដែលមានសរសេរអំពីអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឲ្យ

---

[113] សេចក្តីពន្យល់អំពីនីតិរដ្ឋប្បវេណី ទំព័រ៧៣

[114] សេចក្តីពន្យល់អំពីនីតិរដ្ឋប្បវេណី ទំព័រ៧០

[115] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី៣

[116] សេចក្តីពន្យល់អំពីនីតិរដ្ឋប្បវេណី ទំព័រ៧២

ត្រួតពិនិត្យភស្តុតាងដែលទាក់ទងនិងចំណុចជាក់លាក់ណាមួយ។[117]

បន្ថែមពីនេះទៅទៀត ឯកសារនេះត្រូវសរសេរអំពី មធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ខ្លួនរបស់ភាគីម្ខាងទៀត។[118] នៅក្នុងឯកសារចម្លើយនេះ ត្រូវសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារ និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុ ដែលមានសរសេរក្នុងបណ្តឹងព្រមទាំងការតវ៉ា[119] តែបើសិនចុងចម្លើយមិនបានដាក់ឯកសារចម្លើយនៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់។

ប្រសិនបើចុងចម្លើយបានដាក់ឯកសារចម្លើយ ឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ ដូចជាការស្នើសុំឲ្យតុលាការចេញសាលក្រមលើកចោលនូវការទាមទាររបស់ដើមចោទ ដោយអះអាងអំពីកង្វះខាតលក្ខខណ្ឌនៃបណ្តឹង ឬ ការទាមទារគ្មានមូលហេតុត្រឹមត្រូវ នោះឯកសារនេះគឺជាការឆ្លើយតបចំពោះសំណូមពររបស់ដើមចោទ។

គួរបញ្ជាក់ផងដែរថា តុលាការជាតួអង្គក្នុងការបំពេញភារកិច្ចពិនិត្យ ភស្តុតាង រីឯ ភាគីទាំងនៃវិវាទ ជាអ្នករកភស្តុតាង និងដាក់ភស្តុតាង ដូចជា ភស្តុតាងជាឯកសារ ជាដើម ហើយដាក់មកតុលាការដើម្បីធ្វើការពិនិត្យ ដូចបានធ្វើការបកស្រាយលម្អិតនៅផ្នែកទី១ខាងលើ។

### ២.២.១.២ ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុនៃការដាក់សំណូមពររបស់ខ្លួន ហើយចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការណ៍ចំពោះមូលហេតុនៃការឆ្លើយរបស់ខ្លួន។ សេចក្តីថ្លែងការណ៍របស់ដើមចោទ ហៅថាមធ្យោបាយតទល់ រីឯសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ ហៅថាមធ្យោបាយការពារខ្លួន។ មធ្យោបាយតទល់របស់ដើមចោទគឺជាសេចក្តីថ្លែងការណ៍ដែលអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តបង្កើតឲ្យមានសិទ្ធិដែលជាការទាមទារតាមផ្លូវបណ្តឹង ប៉ុន្តែសិទ្ធិនេះមិនអាចត្រូវបានទទួលស្គាល់ដោយផ្ទាល់បានឡើយ ដូចនេះដើមចោទត្រូវអះអាង អំពីអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិ-

[117] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០២

[118] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី២

[119] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី៣

យុត្ត ដែលជាអានុភាពគតិយុត្តបង្កើតឲ្យមានសិទ្ធិនោះ។ តុលាការត្រូវវិនិច្ឆ័យថាតើសិទ្ធិនោះបានកើតឡើងឬទេ ឬសិទ្ធិនោះធ្លាប់បានកើតឡើងតែត្រូវរលត់ដោយហេតុត្រូវនឹងលក្ខខណ្ឌគតិយុត្តនៃការរលត់សិទ្ធិដែរឬទេ។ ការវិនិច្ឆ័យនេះធ្វើឡើងក្នុងគោលបំណងកំណត់អំពីអត្ថិភាពនៃសិទ្ធិនាពេលបច្ចុប្បន្ន ឬនត្ថិភាពនៃសិទ្ធិនេះ។

មធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ គឺជាសេចក្តីថ្លែងការណ៍ដែលអះអាងតបចំពោះមូលហេតុនៃការទាមទាររបស់ដើមចោទ។ ក្នុងករណីខ្លះ ទោះបីជាអង្គហេតុ ដែលបានលើកឡើងដោយដើមចោទមានពិតប្រាកដមែនក៏ដោយ ប៉ុន្តែប្រសិនបើមានអង្គហេតុដែលបញ្ជាក់ថារលត់សិទ្ធិ (នត្ថិភាពនៃសិទ្ធិ) ដូចជាការសង ការទូទាត់ ឬអាជ្ញាយុកាលនៃការរលត់សិទ្ធិត្រូវបានសម្រេចជាដើម អាចអះអាងបាន។ ការអះអាងរបស់ចុងចម្លើយនេះគឺជាមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ ដែលគេហៅបានថាជាការតវ៉ា។

ដើមចោទអាចធ្វើសេចក្តីថ្លែងការណ៍ដោយអះអាងនូវអង្គហេតុ ដែលអាចលុបចោលនូវអានុភាពនៃការតវ៉ារបស់ចុងចម្លើយ ឬក្នុងករណីដែលដើមចោទបានបដិសេធនូវអង្គហេតុនៃការតវ៉ានោះចុងចម្លើយត្រូវដាក់ភស្តុតាង ដើម្បីស្នើសុំឲ្យតុលាការពិនិត្យ ដើម្បីបញ្ជាក់អពីអង្គហេតុតវ៉ាដែលខ្លួនបានលើកឡើង។

### ២.២.១.៣. ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

ដោយគោរពគោលការណ៍ *"ភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិតនិងស្មោះត្រង់"* នោះភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្តឹង[120]។ ពេលវេលាសមរម្យគឺជា ឱកាស ឬដំណាក់កាលនៃនីតិវិធីដែលគួរដាក់ឯកសារ មធ្យោបាយនោះ ដើម្បីដោះស្រាយវិវាទឲ្យបានឆាប់រហ័ស និងយុត្តិធម៌។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រូវបានធ្វើឡើងដើម្បីឲ្យការវិនិច្ឆ័យបណ្តឹងអាចធ្វើបានដោយសម្ញហវិធី នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តាមរយៈការរៀបចំជាមុននូវការអះអាងរបស់ភាគី ដើម្បីស្វែងរក និងបញ្ជាក់ច្បាស់លាស់នូវចំណុចវិវាទ ព្រមទាំងរៀបចំជាមុននូវភស្តុតាង ដែលត្រូវពិនិត្យនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់-

[120] មាត្រា៨៣ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មាត់។ ដូចនេះភាគីត្រូវដាក់ការអះអាងរបស់ខ្លួន ឬត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀតឲ្យទាន់ពេលវេលា និងសមរម្យទៅតាមដំណើរការនៃបណ្តឹង។ មធ្យោបាយតទល់ឬការពារ ដែលភាគីបានដាក់ដោយមានការយឺតយ៉ាវ ដោយចេតនា ឬដោយកំហុសធ្ងន់ធ្ងររបស់ភាគី និងជាឧបសគ្គដល់នីតិវិធីនៃបណ្តឹង។ ដូចនេះ ប្រសិនបើទទួលស្គាល់នូវគោលការណ៍នេះតុលាការអាចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនមិនត្រឹមតែនាំឲ្យមានការអូសបន្លាយពេលវេលានៃការបញ្ចប់បណ្តឹងទេ វាថែមទាំងជាការរំខានដល់ភាគី និងធ្វើឲ្យមានការខូចខាតដល់ប្រសិទ្ធិភាពនៃប្រព័ន្ធតុលាការទាំងមូលផងដែរ។

ករណីដែលមធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានដាក់ទៅតុលាការតាមពេលវេលាសមរម្យ ប៉ុន្តែប្រសិនបើមធ្យោបាយដែលត្រូវបានដាក់មានអត្ថន័យមិនច្បាស់លាស់ ហើយភាគីមិនបានបំភ្លឺ ឬមិនចូលមកបំភ្លឺតាមកាលបរិច្ឆេទឲ្យចូលមកបំភ្លឺទេ តុលាការអាចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនដែលមិនច្បាស់លាស់នោះបាន[121]។

### ២.២.១.៤. ការស្នើសុំឲ្យពិនិត្យភស្តុតាង

ជាគោលការណ៍ការពិនិត្យភស្តុតាងត្រូវធ្វើឡើងតាមការស្នើសុំឲ្យពិនិត្យរបស់ភាគី[122] ប៉ុន្តែក្នុងករណីដែលតុលាការពុំអាចសម្រេចថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុដោយភស្តុតាងដែលគូភាគីបានស្នើសុំឲ្យពិនិត្យ ឬបើយល់ឃើញថាមានការចាំបាច់ផ្សេងទៀតនោះ តុលាការអាចពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន។[123]

ការស្នើសុំឲ្យពិនិត្យភស្តុតាងអាចធ្វើឡើងនៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញ-ហេតុផលបាន ហើយភាគីដែលស្នើសុំឲ្យពិនិត្យភស្តុតាងត្រូវកំណត់ឲ្យជាក់លាក់ និងបំភ្លឺឲ្យបានច្បាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុនោះ និងភស្តុតាង។[124]

នៅពេលដែលបានទទួលការស្នើសុំឲ្យពិនិត្យភស្តុតាង នោះតុលាការអាចចេញដីកាសម្រេចទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាងបាន ដូចបានបកស្រាយលម្អិតនៅចំណុច ២.២.៣.២. ការ

[121] មាត្រា ៩៨កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[122] មាត្រា ១២៨កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[123] មាត្រា ១២៨កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[124] មាត្រា ១២៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ពិនិត្យភស្តុតាងជាឯកសារខាងលើ។ ប៉ុន្តែចំពោះភស្តុតាងដែលតុលាការយល់ឃើញថាគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ ឬ ភស្តុតាងផ្សេងទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ នោះតុលាការអាចបដិសេធមិនយកមកពិនិត្យបាន។

បន្ទាប់ពីមានការស្នើសុំឲ្យតុលាការពិនិត្យភស្តុតាង ភាគីត្រូវលើកឡើងនូវការអះអាងរបស់ខ្លួនឲ្យទាន់ពេលវេលា ហើយត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត និងត្រូវស្នើសុំដាក់ភស្តុតាងចំពោះអង្គហេតុដែលមានវិវាទ។

### ២.២.១.៥.ការស្នើសុំឲ្យផ្លាស់ប្តូរសមត្ថកិច្ចតុលាការ បណ្តឹងជិតជិត និងការហួតសមត្ថកិច្ចតុលាការ

នៅក្នុងករណីដែលមានការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី ភាគីអាចធ្វើពាក្យសុំដោយបញ្ជាក់ឲ្យច្បាស់អំពីមូលហេតុទៅតុលាការដែលបាននឹងកំពុងដំណើរការនៃរឿងក្តី ក្នុងគោល-បំណងដើម្បីឲ្យតុលាការនោះផ្ទេរបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច។ ជាទូទៅ ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

ក្រៅពីធ្វើពាក្យសុំផ្ទេរសមត្ថកិច្ចដោយមូលហេតុការចាត់ចែងខុសសមត្ថកិច្ចជម្រះក្តី ភាគីក៏អាចធ្វើពាក្យសុំផ្ទេរផងដែរ ក្នុងករណីការផ្ទេរបណ្តឹងដើម្បីជៀសវាងពីការយឺតយ៉ាវ មានន័យថា ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬដើម្បីឲ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សីដែលត្រូវសាកសួរ ទីតាំងវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និងកាលៈទេសៈផ្សេងៗទៀត ដែលក្នុងនោះតុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬផ្នែកណាមួយទៅឲ្យតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចតាមរយៈពាក្យសុំនេះ។

បើទោះបីជាមានដីកាសម្រេចផ្ទេរ និងដីកាសម្រេចលើកចោលពាក្យសុំផ្ទេរក៏ដោយ វាក៏អាចត្រូវបានប្តឹងជំទាស់បានដែរ ក្នុងករណីដែលភាគីមិនពេញចិត្ត។[125] បន្ថែមពីនេះ ប្រសិនបើភាគីមិនបានប្តឹងជំទាស់ក្នុងឱកាសនេះទេ ក្រៅពីនោះ ភាគីមិនយកអសមត្ថកិច្ចរបស់សាលាជម្រះក្តីលើកទី១មកធ្វើជា

[125] មាត្រា ២១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

មូលហេតុនៃបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមចុងក្រោយបានឡើយ លើកលែងករណីនៃការខុសនឹងសមត្ថកិច្ចផ្ដាច់មុខ[126]។

បណ្ដឹងជិតចិត្តក៏អាចត្រូវបានធ្វើឡើងដោយភាគីក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលផង-ដែរ ប៉ុន្តែវាអាចធ្វើបានតែក្នុងករណីដែលភាគីនោះមិនបានដឹងពីមូលហេតុដែលអាចប្ដឹងជិតចិត្ត ឬករណីដែលមូលហេតុនៃបណ្ដឹងជិតចិត្តបានកើតឡើងនៅពេលក្រោយ។[127] បណ្ដឹងនេះធ្វើឡើងក្នុងក្របខណ្ឌដែលមានកាលៈទេសៈដែលបណ្ដាលឲ្យមានការលំអៀងក្នុងការជម្រះក្ដីចំពោះចៅក្រមណាម្នាក់។ ផ្ទុយទៅវិញ ប្រសិនបើភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬបានធ្វើសេចក្ដីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្ដឹងជិតចិត្តចៅក្រមបានឡើយ។[128]

ក្រៅពីនេះ ភាគីក៏អាចធ្វើពាក្យស្នើសុំឲ្យដកសមត្ថកិច្ចជំនុំជម្រះបានដែរ។ ករណីដែលអាចធ្វើការដកហូតសមត្ថកិច្ចបានមានដូចជា៖[129]

- ចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្ដី
- ចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី៦ ឬញាតិពន្ធក្នុងថ្នាក់ទី៣ ឬអតីតញាតិពន្ធក្នុងថ្នាក់ទី៣ របស់ភាគីណាមួយ។
- ចៅក្រមដែលទទួលបន្ទុករឿងក្ដីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- ចៅក្រមបានធ្វើជាសាក្សី ឬធ្វើជាអ្នកជំនាញក្នុងរឿងក្ដី
- ចៅក្រមជាអ្នកតំណាង ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្ដី។

### ២.២.១.៦. ការដកពាក្យបណ្ដឹងរបស់ភាគី

#### ក. អត្ថន័យនៃការដកពាក្យបណ្ដឹង

ការដកពាក្យបណ្ដឹង គឺ ជាសកម្មភាពដកមួយភាគ ឬ ទាំងស្រុងនូវពាក្យសុំទាមទារឲ្យចេញ

[126] មាត្រា ២៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[127] មាត្រា ២៨ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[128] មាត្រា ២៨ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[129] មាត្រា ២១ កថាខណ្ឌទី១ ចំណុច ក ដល់ ចំណុច ឆ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

សាលក្រមតាមរយៈបណ្តឹងដោយដើមចោទ។ បណ្តឹងគឺជាសកម្មភាពដែលដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ហេតុនេះហើយ ការដកពាក្យបណ្តឹងនោះ ក៏ជាគោលការណ៍អាចធ្វើទៅបានតែដោយឆន្ទៈរបស់ដើមចោទប៉ុណ្ណោះ។[130]

## ខ.វិធីដក និងលក្ខខណ្ឌនៃការដកពាក្យបណ្តឹង

ដើមចោទអាចដកពាក្យ បណ្តឹងពេលណាក៏បាន រហូតដល់ពេលដែលសាលក្រមចុងក្រោយចូលជាស្ថាពរ។ ក៏ប៉ុន្តែ ក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្តី មានន័យថា អំពីការទាមទាររបស់ដើមចោទ ឬបានធ្វើសេចក្តីថ្លែងការណ៍អំពីអង្គសេចក្តីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីដកពាក្យបណ្តឹង ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ។[131] ប្រសិនបើពុំមានការយល់ព្រមពីចុងចម្លើយនោះទេ ការដកពាក្យបណ្តឹងពុំមានអានុភាពនោះទេ។ នេះគឺដោយសារតែចុងចម្លើយឆ្លើយតបនឹងការទាមទាររបស់ដើមចោទ មានន័យថាចុងចម្លើយក៏មានផលប្រយោជន៍ក្នុងការទទួលសាលក្រមឈ្នះក្តីចំពោះបណ្តឹងនោះដែរ ដូច្នេះហើយ ការទទួលស្គាល់នូវការបំបាត់នូវផលប្រយោជន៍របស់ចុងចម្លើយ តាមឆន្ទៈរបស់ដើមចោទតែប៉ុណ្ណោះ វានឹងមានភាពផ្ទុយនឹងសមភាព និងយុត្តិធម៌សម្រាប់ចុងចម្លើយ។

ការដកពាក្យពាក្យបណ្តឹង គឺជាសកម្មភាពបណ្តឹងរបស់ដើមចោទ ដែលត្រូវបានធ្វើឡើងនៅក្នុងនីតិវិធីនៃបណ្តឹង។ ហេតុនេះហើយ ត្រូវបែងចែកឲ្យដាច់ពីការព្រមព្រៀងដកពាក្យបណ្តឹងដែលភាគីទាំងសងខាងធ្វើឡើងក្រៅពីនីតិវិធីបណ្តឹង។ ការដកពាក្យបណ្តឹងតាមផ្លូវបណ្តឹងនាំឲ្យ ការចាត់ការបណ្តឹងនឹងត្រូវរលាយ ផ្ទុយទៅវិញ ការព្រមព្រៀងដកពាក្យបណ្តឹងក្រៅនីតិវិធីបណ្តឹង វាគ្រាន់តែជាកិច្ចសន្យាមួយតាមផ្លូវនីតិឯកជនប៉ុណ្ណោះ ហេតុនេះហើយ ពុំអាចបង្កើតនូវអានុភាពតាមផ្លូវច្បាប់ ដូចជា ការរំលាយការចាត់ការបណ្តឹង ជាអាទិ៍ទេ។

បន្ថែមពីនេះទៀត ការដកពាក្យបណ្តឹង ជាគោលការណ៍ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[132] ក៏ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចដកពាក្យបណ្តឹងដោយផ្ទាល់មាត់

[130] មាត្រា ២១៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[131] មាត្រា ២១៧ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[132] មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ក៏បានដែរ។[133] ពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនៅក្នុងកំណត់ហេតុនៃវិធីនីតិត្រៀមទាញហេតុផល ដើម្បីកុំអោយមានការវិវាទនាពេលក្រោយ។ កាលបរិច្ឆេទនៃការផ្សះផ្សា គឺជាផ្នែកមួយនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ហេតុនេះហើយ ក្នុងករណីដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការផ្សះផ្សា ចាំបាច់ត្រូវចុះនូវចំណុចនេះនៅក្នុងកំណត់ហេតុ (កំណត់ហេតុសះជា)។

ក្នុងករណីដែលចាំបាច់មានការយល់ព្រមពីចុងចម្លើយដើម្បីដកពាក្យបណ្តឹង ហើយទោះជាចុងចម្លើយមិនយល់ព្រមជាក់ស្តែងក៏ដោយក៏ត្រូវចាត់ទុកដូចជាមានការយល់ព្រមដែរ ដូចក្នុងករណីខាងក្រោម៖

- ទីមួយ៖ ករណីដែលដើមចោទដាក់លិខិតដកពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូននូវលិខិតនេះទៅឲ្យចុងចម្លើយ។[134] ប្រសិនបើចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល២សប្តាហ៍គិតពីថ្ងៃដែលបានទទួលនូវការបញ្ជូនលិខិតនោះទេ ត្រូវចាត់ទុកថាបានយល់ព្រមចំពោះការដកពាក្យបណ្តឹងនេះហើយ។[135]
- ទីពីរ៖ ក្នុងករណីដែលដើមចោទបានដកពាក្យបណ្តឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬកាលបរិច្ឆេទនៃការផ្សះផ្សា តែចុងចម្លើយអវត្តមាននៅកាល-បរិច្ឆេទនោះ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុដែលបានចុះសេចក្តីថ្លែងការណ៍អំពីការដកពាក្យពាក្យបណ្តឹងនោះទៅឲ្យចុងចម្លើយ។ ក្នុងករណីដែលចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល២សប្តាហ៍ពីថ្ងៃដែលបានទទួលនូវការបញ្ជូននោះ ក៏ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះដែរ។[136]
- ទីបី៖ ក្នុងករណីដែលដើមចោទបានដកព្យបណ្តឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទត្រៀម-សម្រាប់ទាញហេតុផល ហើយចុងចម្លើយមានវត្តមាននៅកាលបរិច្ឆេទនោះ ប្រសិនបើចុង-ចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល២សប្តាហ៍ គិតពីកាលបរិច្ឆេទនោះ ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះ។

[133] មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[134] មាត្រា ២១៧ កថាខណ្ឌទី៤ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[135] មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[136] មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

### គ.ការសងពន្ធដាក់ពាក្យបណ្តឹង

ប្រសិនបើដើមចោទបានដកពាក្យបណ្តឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលលើកដំបូង ភាគីអាចទាមទារឲ្យតុលាការសងមកវិញនូវចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងដែលខ្លួនបានបង់។[137]

## ២.៣. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលក្រោយៗទៀត

បន្ទាប់ពីដើមចោទបានធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងហើយ ចុងចម្លើយត្រូវធ្វើការអះអាងពីការតវ៉ាប្រសិនបើមាន។ ដើមចោទក៏ត្រូវដាក់ឯកសារត្រូវស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់ ព្រមទាំងការតវ៉ាចំពោះការអះអាងរបស់ចុងចម្លើយដែរ។ ប្រសិនបើការអះអាងរបស់ភាគីទាំងសងខាងនឹងបានធ្វើឡើងគ្រប់គ្រាន់ ភាគីទាំងសងខាងត្រូវស្នើសុំឲ្យពិនិត្យភស្តុតាងទៅលើសាក្សី និងសាមីភាគីព្រមទាំងភស្តុតាងជាឯកសារ។ បន្ទាប់មកតុលាការត្រូវកំណត់កាលបរិច្ឆេទលើកទី២ ហើយតុលាការអាចជូនដំណឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទលើកទី១នោះតែម្តង។

### ២.៣.១. សេចក្តីថ្លែងការណ៍

#### ២.៣.១.១. សេចក្តីថ្លែងការណ៍អំពីឯកសារត្រៀមលើកទី១

ដើមចោទបានដាក់ឯកសារត្រៀមទី១ជាមុន ក្រោយពីបានទទួលបង្គាប់ពីចៅក្រមនូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១។ ខ្លឹមសារនៃឯកសារត្រៀមទី១នោះនឹងត្រូវបានថ្លែងការណ៍នៅក្នុងការបរិច្ឆេទសម្រាប់ការទាញហេតុផលលើកទី២។

#### ២.៣.១.២. សេចក្តីថ្លែងការណ៍ពីភស្តុតាង

##### ក. ភស្តុតាងជាឯកសារ

បន្ទាប់ពីបានទទួលការបង្គាប់ពីចៅក្រមអំពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដើមចោទមានសិទ្ធិស្នើសុំតុលាការឲ្យពិនិត្យឯកសារជាភស្តុតាងដើម និងដាក់ឯកសារពន្យល់អំពីភស្តុតាងជូនតុលាការ ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់អំពីទំនាក់ទំនងនៃអង្គហេតុដែលត្រូវ

[137] មាត្រា ៦១ កថាខណ្ឌទី៨ ចំណុចខ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

បញ្ជាក់ដោយភស្តុតាង។ បន្ទាប់មកទៀតតុលាការនឹងធ្វើការត្រួតពិនិត្យទៅឯកសារជាភស្តុតាងនោះ ប្រសិនបើពិនិត្យទៅឃើញថា ឯកសារជាភស្តុតាងពុំមានលក្ខណៈមិនត្រឹមត្រូវទេ នោះតុលាការនឹងចេញសេចក្តីសម្រេចច្រានចោលទៅលើការស្នើសុំនោះ។ ផ្ទុយទៅវិញ បើពិនិត្យទៅឃើញថា ឯកសារជាភស្តុតាងមានភាពត្រឹមត្រូវ តុលាការនឹងបញ្ជូនឯកសារចម្លងនោះទៅក្នុងសំណុំរឿង។

ក្រៅពីនោះ ភាគីចុងចម្លើយក៏មានសិទ្ធិស្នើសុំឲ្យតុលាការពិនិត្យភស្តុតាងជាឯកសារដែរ។ ចំពោះនីតិវិធីនៅក្នុងការស្នើសុំការទទួលយក ឬមិនទទួលយកការបញ្ជាប់ភស្តុតាង ក៏ដូចគ្នានឹងការបកស្រាយនៅផ្នែកខាងលើ។

### ខ.នីតិវិធីស្នើសុំឲ្យពិនិត្យភស្តុតាងទៅលើសាក្សី និងសាមី ភាគី រហូតដល់ពេលត្រៀមធ្វើការពិនិត្យ

- **ការស្នើសុំឲ្យសុំពិនិត្យភស្តុតាង**

ភាគីដែលស្នើសុំឲ្យពិនិត្យភស្តុតាងត្រូវបំពេញកាតព្វកិច្ចពីរដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីគឺ៖

- ភាគីត្រូវកំណត់ជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់
- ភាគីត្រូវបំភ្លឺឲ្យច្បាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុនោះ និងភស្តុតាង។

ចំពោះភាគីស្នើសុំសាកសួរសាក្សី (សាកសួរសាមីភាគី) ក៏ត្រូវបំពេញកាតព្វកិច្ចពីរផងដែរដូចជា៖

- ភាគីស្នើសុំត្រូវកំណត់ឲ្យច្បាស់លាស់អំពីសាក្សី (សាមីភាគី)។
- ភាគីដែលស្នើសុំ (សាកសួរសាមីភាគី) ត្រូវភ្ជាប់ជាមួយផងដែរនូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសាកសួរ។

- **នីតិវិធីចេញដីកាសម្រេចទទួលយកពាក្យសាកសួរសាមីភាគី និងសាក្សី**

តុលាការមានសិទ្ធិសម្រេចទទួលយក ឬមិនទទួលយកនូវភស្តុតាងដែលភាគីស្នើសុំដោយភាគី។ តុលាការពុំអាចធ្វើការត្រួតពិនិត្យភស្តុតាងលើសាក្សី និងសាមីភាគីបានទេនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផល ដោយការត្រួតពិនិត្យនេះត្រូវធ្វើឡើងក្នុងដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់។ ដូច្នេះ យើងសង្កេតឃើញថាចំណុចនេះមានលក្ខណៈខុសប្លែកពីការពិនិត្យភស្តុតាងជាឯកសារ ដែលអាចធ្វើការពិនិត្យនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។ ដើម្បីប្រព្រឹត្តទៅយ៉ាងរលូននៃការសាកសួរសាក្សី និងសាមីភាគីនៅក្នុងនីតិត្រៀមសម្រាប់ទាញហេតុផល គប្បីសាកសួរបញ្ជាក់ភាគីនូវសំណួរមួយថាតើត្រូវធ្វើការសាកសួរសាក្សី និងសាមីភាគីដោយលំដាប់-លំដោយតាមរបៀបណានៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់។

# ជំពូកទី៣៖ ការបញ្ចប់ និងអានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## ៣.១. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ៣.១.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនេះ[138]។ នៅត្រង់ចំណុចនេះ មានន័យថា តុលាការ និងភាគីទាំងសងខាង ត្រូវធ្វើការបញ្ជាក់ថាតើការអង្គហេតុណាខ្លះដែលជាចំណុចវិវាទហើយ ដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយតុលាការ និងភាគីសងខាង ត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បាន។[139] ការជូនដំណឹងអំពីដីកាសម្រេច អាចធ្វើដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ អាចធ្វើតាមរយៈទូរស័ព្ទ ឬ ទូរសារ ជាដើម។

### ៣.១.២. ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់

ជាបន្ទាប់មកទៀត នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយមានការបញ្ជាក់អំពីអង្គហេតុ ដែលត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់លាស់រួចមក តុលាការត្រូវកំណត់ កាលបរិច្ឆេនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយតុលការត្រូវកោះហៅភាគីទាំងសងខាង ឲ្យអញ្ជើញមកចូលរួមនៅកាលបរិច្ឆេទដែលបានកំណត់។[140] ជាគោលការណ៍ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នឹងប្រព្រឹត្តឡើងបន្ទាប់ពីនីតិវិធីដ៏សំខាន់ គឺ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់សព្វគ្រប់ដោយតុលាការ។

[138] មាត្រា១០៧ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

[139] មាត្រា១២៧ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

[140] មាត្រា១១៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

## ៣.២. អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ៣.២.១. ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

នៅពេលដែលនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលបានបញ្ចប់នោះគឺចំណុចវិវាទ និងភស្តុតាងដែលត្រូវពិនិត្យត្រូវបានរៀបចំជាស្រេច ដូចនេះភាគីមិនអាចដាក់មធ្យោបាយតទល់ឬការពារខ្លួនថ្មីបានទៀតឡើយ។លើកលែងតែមធ្យោបាយតទល់ឬការពារខ្លួន ឬករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថាខ្លួនមិនអាចដាក់មធ្យោបាយនោះបានមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ[141]។ ប្រសិនបើអនុញ្ញាតឲ្យភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្រោយការបញ្ចប់នីតិវធីត្រៀមសម្រាប់ការទាញហេតុហេតុផលបាននោះ ការដែលត្រូវបានកំណត់ចំណុចវិវាទឲ្យរួចរាល់តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និងការបង្រួមភស្តុតាងដែលត្រូវពិនិត្យ និងពុំមានខ្លឹមសារអ្វីឡើយ។ បើគិតតាមគោលការណ៍នៃការដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលសមរម្យ(មាត្រា៩៣ ក្រមនីតិវិធីរដ្ឋប្បវេណី)ភាគីត្រូវដាកមធ្យោបាយតទល់ ឬការពារខ្លួនក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

### ៣.២.២. ករណីលើកលែង

ទោះបីជាមានការកំណត់ដូចខាងលើនេះក៏ដោយក៏ភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលក្រោយបាន ក្នុងករណីដែលបញ្ហាពាក់ព័ន្ធ គឺជាចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។ ករណីដែលភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនបានមានដូចជាៈ

- ភាពមិនប៉ះពាល់ដល់នីតិវិធីៈ នៅត្រង់ចំណុចនេះមានន័យថា ការដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលក្រោយ គឺមិនមានឥទ្ធិពលដែលនាំឲ្យនីតិវិធីមានបញ្ហា ឬមិនដំណើរការ។ និយាយម្យ៉ាងទៀតថា ប្រសិនបើតុលាការយល់ឃើញថា ការដាក់ ឬការពារខ្លួននោះមិននាំឲ្យមានភាពយឺតយ៉ាវដល់នីតិវិធីទេ នោះតុលាការអាចអនុញ្ញាតឲ្យភាគីធ្វើអញ្ចឹងបាន។

[141] មាត្រា១០៨ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

- គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់៖ ជាគោលការណ៍ ទោះបីជានីតិវិធីត្រូវបានបញ្ចប់ក៏ដោយ ភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនបាន ក្នុងករណីដែលតុលាការយល់ឃើញថាសកម្មភាពនោះបង្ហាញភាពស្មោះត្រង់ មិនភូតកុហក និងប្រកបដោយសុចរិតភាព។

**<u>ឧទាហរណ៍</u>**៖ អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចរបស់តុលាការ ឬ អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះជាអាទិ៍។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយអំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួមក យើងឃើញថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ជាដំណាក់កាលសំខាន់បន្ទាប់ពីការដាក់ពាក្យបណ្តឹង ហើយនីតិវិធីនេះមានគោលបំណងសំខាន់ៗដែលរួមមានដូចជា៖ ដើម្បីបង្រួមអង្គហេតុ រៀបចំចំណុចវិវាទ និងការដាក់ភស្តុតាង ដែលតាមរយៈនេះភាគីអាចដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន ដើម្បីដាក់ជូនតុលាការពិនិត្យ។ នៅក្នុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តី ដែលភាគីមមិនយល់ស្របគ្នានិងរៀបចំភស្តុតាង ដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បានល្អិតល្អន់។ ម្យ៉ាងវិញទៀត ចំពោះការដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយចេតនាទុចរិត ឬមិនស្មោះត្រង់របស់ភាគី នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើយ។ បញ្ហានេះតែងតែកើតមានជាញឹកញាប់ ដែលភាគីណាមួយមិនគោរពគោលការណ៍ស្មោះត្រង់ ឬសុចរិតតែងតែឆ្លៀតឱកាសធ្វើសកម្មភាពផ្សេងនៅពេល ដែលតុលាការព្រមទទួលយកនូវសកម្មភាពទាំងនោះ ហើយបានបង្កឲ្យមានភាពខូចខាតធ្ងន់ធ្ងរទៅលើភាគីម្ខាងទៀត។ សកម្មភាពទាំងនោះបានបង្កឲ្យភាគីម្ខាងទៀតមិនអាចមានឱកាសសម្រាប់ការពារខ្លួន ឬការតទល់ ហើយទោះបីជាយ៉ាងនេះក្តី ក៏សិទ្ធិនៃការដាក់មធ្យោបាយការពារ ឬតទល់ត្រូវបានទទួលស្គាល់ចំពោះភាគីដែលសុចរិត ក្នុងករណីដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ហើយក៏ដោយ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះមានសារៈសំខាន់ណាស់នៅក្នុងនីតិវិធីរដ្ឋប្បវេណី ពីព្រោះដើម្បីឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់ឲ្យប្រព្រឹត្តទៅមានភាពរលូន និងល្អប្រសើរនោះត្រូវធ្វើយ៉ាងណាឲ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានភាពច្បាស់លាស់ និងគោរពតាមបញ្ញាត្តិច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន។

សរុបសេចក្តីមកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានលើកយកមកបកស្រាយនៅពេលនេះថ្វីត្បិតតែបកស្រាយមិនបានគ្រប់ជ្រុងជ្រោយ តែសង្ឃឹមថាការបកស្រាយនេះនិងអាចជាពន្លឺមួយសម្រាប់ជាជំនួយស្មារតីនៅពេលដែលជួបបញ្ហានៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុនេះជាក់ជាពុំខាន។

# ឯកសារយោង

## ច្បាប់ និង បទបញ្ញត្តិផ្សេងៗ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣។

២. ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦។

៣. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧។

៤. គោលការណ៍ជាមូលដ្ឋានស្ដីពីឯករាជ្យភាពនៃក្រុមចៅក្រម ដែលអនុម័តដោយអង្គការសហប្រជាជាតិ

## សៀវភៅ និង ឯកសារផ្សេងៗ

៥. លោកមេធាវី អ៊ីវ ប៉ូលី.២០១០. *នីតិវិធីរដ្ឋប្បវេណី (មេរៀនសង្ខេប).* ភ្នំពេញ

៦. ក្រសួងយុត្តិធម៌.២០០៩. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ* ១. ភ្នំពេញ៖ ក្រសួងយុត្តិធម៌

៧. ក្រសួងយុត្តិធម៌.២០០៩. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ* ១. ភ្នំពេញ៖ ក្រសួងយុត្តិធម៌

៨. សន្ទានុក្រមពាក្យច្បាប់ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

៩. សាស្ត្រាចារ្យ ហ៊ឹ សោភា នីតិវិធីរដ្ឋប្បវេណី ២០០៧

១០. សាស្ត្រាចារ្យ យឹម សារី នីតិវិធីរដ្ឋប្បវេណី ២០០៧